**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍

# កម្ពុជា និង ថៃ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **សុខ ហេង**

**ឈុន ម៉ិនហុង**

សាស្ត្រាចារ្យណែនាំៈ

លោកស្រី **ទី សុឃីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២១**

ឆ្នាំចូលសិក្សា **២០១៧**

ឆ្នាំសរសេរសារណា **២០២១**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **ឈុន ម៉ិនហុង** និង **សុខ ហេង** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២១ ឆ្នាំសិក្សា ២០១៧ ដល់ ២០២០។ សូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅ និងមិនអាចបំភ្លេចបានជូនចំពោះ៖

អ្នកមានគុណទាំងបួន បងប្អូនប្រុស-ស្រី របស់យើងខ្ញុំទាំងពីរនាក់ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា តាំងពីតូចរហូតដល់ធំ ព្រមទាំងផ្តល់នូវសេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅដល់កូនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ មិនតែប៉ុណ្ណោះ តែងតែផ្តល់នូវការផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងផ្នែកសម្ភារៈសិក្សា និងខាងស្មារតីលើកទឹកចិត្តគាំទ្រដល់កូន រហូតដល់យើងខ្ញុំទាំងពីរនាក់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ។

រាជរដ្ឋាភិបាល ក្រសួងអប់រំ និងឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យគ្រប់ៗរូប នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំពង្រឹងវិស័យអប់រំ និងបង្ហាត់បង្រៀនដោយស្មោះអស់ពីកម្លាំងកាយចិត្ត ក្នុងការផ្តល់នូវចំណេះដឹងយ៉ាងទូលំទូលាយជាមួយនឹងដំបូន្មានដ៏ល្អ ព្រមទាំងបទពិសោធន៍ដ៏មានតម្លៃមិនកាត់ថ្លៃបាន។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមគោរពថ្លែងអំណរគុណ និងសូមគោរពជូនដល់លោកអ្នកមានគុណទាំងបួន ឯកឧត្តម សាស្តាចារ្យ សិស្សច្បង មិត្តភក្តិ និងបងប្អូនប្រុស-ស្រី ទាំងអស់ ឲ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុវណ្ណៈសុខៈពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាផ្នែកនីតិសាស្ត្រ អស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរនាក់មានសេចក្ដីរីករាយនិងសោមនស្សដែលសាកលវិទ្យាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានផ្ដល់ឱកាសឲ្យខ្ញុំទាំងពីរនាក់បានសរសេរចងក្រងនូវសារណាក្នុងការបញ្ចប់ការសិក្សាមួយនេះឡើង។

ដើម្បីរួមចំណែកនៅក្នុងការលើកកម្ពស់នៃការស្រាវជ្រាវដើម្បីចងក្រងទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ យើងខ្ញុំទាំងពីរនាក់បានស្រាវជ្រាវទៅលើសារណាមួយដែលមានប្រធានបទស្ដីពី នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ប្រធានបទស្រាវជ្រាវខាងលើ បានធ្វើឡើងដើម្បីជួយដល់និស្សិតនៅក្នុងការសិក្សាពីភាពខុសគ្នានិងភាពដូចគ្នានៃនីតិអាពាហ៍ពិពាហ៍នៃព្រះរាជាណាចក្រកម្ពុជាទៅនឹងអាពាហ៍ពិពាហ៍នៃព្រះរាជាណាចក្រថៃ។ ការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់បានទទួលការណែនាំពីលោកស្រីសាស្ត្រចារ្យ ដែលបានដឹកនាំនៅក្នុងការស្វែងរកឯកសារនិងបានផ្ដល់ជាគំនិតនៅក្នុងការសរសេរសារណាមួយនេះ។

ខ្ញុំបាទទាំងពីរនាក់ជឿជាក់យ៉ាងមុតមាំថា សារណាមួយនេះជាឯកសារសំខាន់ដែលជាជំនួយដល់សិស្សនិស្សិតក្នុងការយល់ដឹងបន្ថែមទៀតស្ដីពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ក៏សូមអភ័យទោសជាមុននូវរាល់កំហុសឆ្គងទាំងឡាយដែលអាចកើតមានឡើងនៅក្នុងការចងក្រងសារណាមួយនេះ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**......................................................................................................................១

**ជំពូកទី១**
**ការបង្កើតកំជាប់ពាក្យកម្ពុជា និង ថៃ**

១.១ កំជាប់ពាក្យកម្ពុជា..........................................................................................................៣
១.១.១ ការបង្កើតកំជាប់ពាក្យ....................................................................................................៣
១.១.១.១ ការព្រមព្រៀងរបស់គូភាគី..........................................................................................៣
១.១.១.២ ពិធីកំជាប់ពាក្យ.......................................................................................................៤
១.១.២ អនុភាពនៃកំជាប់ពាក្យ....................................................................................................៦
១.១.២.១ ការទទួលខុសត្រូវនៅពេលរំលាយកំជាប់ពាក្យ...............................................................៦
ក. ការទាមទាមឲ្យសងជំនួន......................................................................................................៦
ខ. ការទាមទារសំណងនៃការខូចខាត..........................................................................................៧
គ. ភស្តុតាងនៃកំជាប់ពាក្យ........................................................................................................៧
ឃ. ភស្តុតាងនៃកំហុស.............................................................................................................៧
ង. អំឡុងពេលទាមទារ............................................................................................................៧
១.១.២.២ អនុភាពចំពោះបុត្តភាពដែលកើតចេញពីកំជាប់ពាក្យ....................................................៨
១.២ កំជាប់ពាក្យថៃ..................................................................................................................៨
១.២.១.ការបង្កើតកំជាប់ពាក្យ.....................................................................................................៨
១.២.១.១ លក្ខខណ្ឌអាយុនៃកំជាប់ពាក្យ.....................................................................................៨
១.២.១.២ ការធ្វើពិធីកំជាប់ពាក្យ................................................................................................៩
១.២.២ អនុភាពនៃកំជាប់ពាក្យ..................................................................................................១០
១.២.២.១ ការទាមទារសំណង..................................................................................................១០
ក. ការទាមទារសំណងក្នុងករណីភាគីបំពានកិច្ចសន្យា.................................................................១០
ខ. ការទាមទារសំណងពីតតិយជន.............................................................................................១១

១.២.២.២ ការទាមទារជំនួន........................................................................១១
១.២.២.៣ អំឡុងពេលទាមទារ.....................................................................១១

## ជំពូកទី២

## នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ខ្មែរ

២.១ លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍.................................................................១២
២.១.១ លក្ខខណ្ឌច្បាប់..........................................................................................១២
២.១.១.១ លក្ខខណ្ឌអាយុ.........................................................................................១២
២.១.១.២ លក្ខខណ្ឌទ្វេពន្ធភាព.................................................................................១៣
២.១.១.៣ លក្ខខណ្ឌវិធវភាព.....................................................................................១៣
២.១.១.៤ ការហាមឃាត់រវាងញាតិពន្ធ........................................................................១៤
២.១.១.៥ ការហាមឃាត់រវាងញាតិលោហិត...................................................................១៥
២.១.១.៦ លក្ខខណ្ឌទាក់ទងនឹងការព្រមព្រៀង................................................................១៥
២.១.១.៧ លក្ខខណ្ឌទាក់ទងនឹងសមត្ថភាព....................................................................១៥
២.១.២ លក្ខខណ្ឌទម្រង់........................................................................................១៦
២.១.២.១ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍................................................................១៦
២.១.២.២ ការប្រកាសជាសាធារណៈ.............................................................................១៧
២.១.២.៣ រយៈពេលប្ដឹងជំទាស់..................................................................................១៧
២.១.២.៤ ការចុះសំបុត្រអាពាហ៍ពិពាហ៍.........................................................................១៧
២.២ អនុភាពនៃអាពាហ៍ពិពាហ៍...................................................................................១៨
២.២.១ សិទ្ធិរបស់សហព័ទ្ធ.......................................................................................១៨
២.២.១.១ ការប្រើប្រាស់នាមត្រកូល...............................................................................១៨
២.២.១.២ ការទទួលបាននីតិភាព.................................................................................១៩
២.២.១.៣ ការជ្រើសរើសវិជ្ជាជីវៈ...................................................................................១៩
២.២.១.៤ ការអាស្រ័យនៅទ្រព្យដោយឡែករបស់សហព័ទ្ធ....................................................១៩
២.២.១.៥ ការបង្កើតរបបស្នុំកូនពេញលេញ.....................................................................២០
២.២.១.៦ ការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិ..........................................................................២០
ក.ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា..................................................................២០

ខ. ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់......................................................................២១
ខ.១ ទ្រព្យសម្បត្តិដោយឡែក..........................................................................២១
ខ.២ ទ្រព្យសម្បត្តិរួម......................................................................................២២
ខ.២.១ ការគ្រប់គ្រងទ្រព្យសម្បត្តិរួម.................................................................២៣
ខ.២.២ ការចាត់ចែងទ្រព្យសម្បត្តិរួម.................................................................២៤
២.២.២ ករណីយកិច្ចរបស់សហព័ទ្ធ...............................................................................២៤
២.២.២.១ ករណីយកិច្ចរួមរស់ជាមួយគ្នា...............................................................................២៤
២.២.២.២ ករណីយកិច្ចបង្ការអំពើហិង្សានៅក្នុងគ្រួសារ.................................................................២៤
២.២.២.៣ ករណីយកិច្ចខុសត្រូវរួមរបស់សហព័ទ្ធ.......................................................................២៤

## ជំពូកទី ៣
## នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋថៃ និង ថៃ

៣.១ លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍..............................................................................២៦
៣.១.១ លក្ខខណ្ឌច្បាប់...........................................................................................២៦
៣.១.១.១ លក្ខខណ្ឌអាយុ..........................................................................................២៦
៣.១.១.២ លក្ខខណ្ឌទ្វេពន្ធភាព...................................................................................២៧
៣.១.១.៣ លក្ខខណ្ឌទាក់ទងនឹងញាតិ.............................................................................២៩
៣.១.១.៤ លក្ខខណ្ឌទាក់ទងនឹងកូនសុំ.............................................................................៣០
៣.១.១.៥ លក្ខខណ្ឌទាក់ទងនឹងភេទ..............................................................................៣០
៣.១.១.៦ លក្ខខណ្ឌវិធវភាព.......................................................................................៣១
៣.១.១.៧ លក្ខខណ្ឌមិនមានវិបល្លាសស្មារតី......................................................................៣២
៣.១.២ លក្ខខណ្ឌទម្រង់............................................................................................៣២
៣.១.២.១ ការប្រកាសជាសាធារណៈ................................................................................៣២
៣.១.២.២ ការចុះសំបុត្រអាពាហ៍ពិពាហ៍...........................................................................៣៣
៣.២ អនុភាពនៃការរៀបអាពាហ៍ពិពាហ៍..............................................................................៣៣
៣.២.១ ករណីយកិច្ចរួមរស់ជាមួយគ្នា................................................................................៣៣
៣.២.២ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ.................................................................................៣៤

៣.២.២.១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា.....................................................................៣៤
៣.២.២.២ប្រព័ន្ធទ្រព្យសម្បត្តិតាមការកំណត់របស់ច្បាប់។...................................................៣៥
ក. ទ្រព្យសម្បត្តិដោយឡែក..........................................................................៣៥
ខ. ទ្រព្យសម្បត្តិរួម.....................................................................................៣៦
ខ១. ការគ្រប់គ្រងទ្រព្យសម្បត្តិរួម..............................................................៣៨
ខ២. ការចាត់ចែងទ្រព្យសម្បត្តិរួម..............................................................៣៩
៣.២.២.៣ ការទទួលខុសត្រូវរួមចំពោះកាតព្វកិច្ច..................................................៤០
**សេចក្តីសន្និដ្ឋាន**..........................................................................................៤២
**អនុសាសន៍**.................................................................................................៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ គឺជាប្រទេសភូមិផងរបងជាមួយគ្នាដែលស្ថិតនៅតំបន់អាស៊ីប៉ែកអាគ្នេយ៍ព្រមទាំងជាប្រទេសដែលជាសមាជិកអាស៊ានជាមួយគ្នាថែមទៀតផង។ ប្រទេសកម្ពុជានិងប្រទេសថៃមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធគ្នាល្អខាងផ្នែកសេដ្ឋកិច្ច ការទូត នយោបាយព្រមទាំងកិច្ចសហការប្រតិបត្តិការផ្នែកពាណិជ្ជកម្មនានាទោះបីជាប្រទេសទាំងពីរធ្លាប់មានភាពល្អក់កករអំពីទំនាស់ព្រំដែនរហូតដល់ជម្លោះបង្កឲ្យមានការផ្ទុះអាវុធជាមួយគ្នាយ៉ាងណាក្តី។

បើត្រឡប់ទៅក្រឡេកមើលផ្នែកប្រពៃណី វប្បធម៌ ទំនៀមទំលាប់នៃប្រទេសទាំងពីរវិញ គេអាចសន្និដ្ឋានបានថាប្រពៃណី វប្បធម៌ ទំនៀមទំលាប់នៃប្រទេសទាំងពីរគឺមានលក្ខណៈសឹងតែដូចគ្នាគ្រាន់តែប្រពៃណីទំនៀមទំលាប់នៃប្រទេសទាំងពីរមានលក្ខណៈពិសេសរៀងៗខ្លួន។ នៅក្នុងសង្គមខ្មែរ ពិធីរៀបមង្គលការគឺជាប្រពៃណីមួយដែលមានបញ្ញត្តិប្រហែលគ្នានឹងកាតព្វកិច្ចដែរ ព្រោះអ្នកដែលយកគ្នាជាប្តីប្រពន្ធត្រូវតែរៀបការបើគេចវេះពិធីនេះនឹងត្រូវចាត់ទុកជាគ្មានសិរីសួស្តីគ្មានកិត្តិយស។ ទម្រង់អាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ នៅមុនពេលការរៀបអាពាហ៍ពិពាហ៍គេតែងតែមានប្រារព្ធពិធីចៃចូវ ពិធីស្តីដណ្តឹង ពីធីជូនកំណត់ បើនៅពេលអាពាហ៍ពិពាហ៍វិញគេតែងតែមានពិធីផ្សេងៗដូចជាថ្ងៃចូលរោងថ្ងៃស៊ីកំណត់និងថ្ងៃសំពះ។ រីឯប្រពៃណីទំនៀមទំលាប់នៃការរៀបអាពាហ៍ពិពាហ៍នៃប្រទេសថៃវិញគឺមានលក្ខណៈនិងទិដ្ឋភាពខុសគ្នាពីការរៀបអាពាហ៍ពិពាហ៍ប្រពៃណីទំនៀមទំលាប់នៃអាពាហ៍ពិពាហ៍កម្ពុជា។ផ្អែកទៅតាមទំនៀមទំលាប់ប្រពៃណីនៃប្រទេសថៃនៅពេលមានការរៀបចំរៀបអាពាហ៍ពិពាហ៍គេតែងមានពិធីកំជាប់ពាក្យតាមប្រពៃណីបុរាណ ពិធីរាប់បណ្ណាការ ពិធីឃាំងកូនប្រុសមុននឹងកូនប្រុសនាំកូនស្រីមកធ្វើពិធីកំជាប់ពាក្យ ឬដើម្បីរៀបអាពាហ៍ពិពាហ៍ ។

ដោយហេតុតែប្រទេសទាំងពីរមានភូមិផងរបងជាមួយគ្នាព្រមទាំងប្រពៃណីទំនៀមទំលាប់នៃប្រទេសទាំងពីរមានលក្ខណៈស្រដៀងគ្នា ទើបក្រុមយើងខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៅទិដ្ឋភាពខាងផ្នែកផ្លូវច្បាប់នៃការរៀបអាពាហ៍នៃប្រទេសទាំងពីរ។

ជាតាក់តាង អាពាហ៍ពិពាហ៍តាមលក្ខណៈបែបផែនប្រពៃណីនៃប្រទេសទាំងពីរមានលក្ខណៈស្រដៀងគ្នាចុះលក្ខណៈផ្លូវច្បាប់វិញមានលក្ខណៈបែបណាដែរនៃប្រទេសទាំងពីរ។

តើដើម្បីឲ្យអាពាហ៍ពិពាហ៍មួយដែលស្របទៅតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រថៃនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា តើប្រជាពលរដ្ឋខ្មែរនិងជាពិសេសប្រជាពលថៃត្រូវបំពេញលក្ខខណ្ឌតាមផ្លូវច្បាប់បែបណាខ្លះទើបធ្វើឲ្យអាពាហ៍ពិពាហ៍មានសុពលភាពនិងមានអនុភាពតាមផ្លូវច្បាប់។

នៅពេលអាពាហ៍ពិពាហ៍មួយដែលត្រូវបានបង្កើតឡើងស្របទៅតាមលក្ខខណ្ឌគតិយុត្តិតើនឹងមានអនុភាពយ៉ាងដូចម្តេចខ្លះទាំងអាពាហ៍ពិពាហ៍កម្ពុជានិងអាពាហ៍ពិពាហ៍ថៃ។

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍កម្ពុជា និង ថៃ យើងខ្ញុំបានធ្វើការបែងចែកជាពីរជំពូកដូចខាងក្រោមគឺ ៖

ជំពូកទី១. ការធ្វើកំជាប់ពាក្យកម្ពុជានិងថៃ

ជំពូកទី២. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងខ្មែរ

ជំពូកទី៣. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋថៃនិងថៃ

# ជំពូកទី១ ពិធីកំជាប់ពាក្យកម្ពុជា និង ថៃ

## ១.១. កំជាប់ពាក្យកម្ពុជា

នៅប្រទេសកម្ពុជាយើងប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទំលាប់ក្នុងការប្រារព្ធពិធីផ្សេងៗ ក្នុងនោះក៏មានពិធីរៀបអាពាហ៍ពិពាហ៍ផងដែរ។ តាមទំនៀមទំលាប់ពីបុរាណមុនឈានដល់ការរៀបអាពាហ៍ពិពាហ៍គឺត្រូវឆ្លងកាត់នូវច្រើនដំណាក់កាលដែលក្នុងនោះរួមមានពិធីកំជាប់ពាក្យជាដើមប៉ុន្តែក៏អាស្រ័យទៅតាមស្ថានភាពនៅក្នុងគ្រួសារ និងទីកន្លែងនៃអាពាហ៍ពិពាហ៍នោះ។ ទោះបីជាយ៉ាងណាក៏ដោយទាំងនេះគ្រាន់តែជាការបំពេញតាមទំនៀមទំលាប់តែប៉ុណ្ណោះ ពោលគឺពុំទាន់បានក្លាយជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។

យោងតាមកាលវិភាគតាមបែបសង្គមសាស្ត្រ ការធ្វើកំជាប់ពាក្យមានចរិតលក្ខណៈមិនខុសពីដំណាក់កាលរៀបចំ ឬត្រៀមខ្លួនឆ្លងកាត់កាលពីរបន្តបន្ទាប់ រវាងអន្តរកាលនៅលីវឈានឆ្ពោះទៅកាន់ជីវិតអាពាហ៍ពិពាហ៍។ ដំណាក់កាលនេះស្តែងចេញ ជារូបភាពអនុវត្តន៍ផ្សេងៗគ្នាទៅតាមតំបន់ភូមិសាស្ត្រសម័យកាលនិងប្រពៃណីទំនៀមទំលាប់។ សំរាប់វណ្ណៈអភិជនការភ្ជាប់ពាក្យគឺជាការប្រកាសគំរោងអាពាហ៍ពិពាហ៍ចូលក្នុងសង្គមនឹងតាមរយៈការខិតខំត្រៀមទាំងផ្នែកចិត្តសាស្ត្រ ក៏ដូចជាខាងផ្នែកសំភារៈរហូតទៅដល់មានការប្រារព្ធពិធីតាមបែបសាសនានៃការភ្ជាប់ចំណងនៃពេលអនាគត។ សំរាប់បណ្តាប្រទេសនៅប៉ែកខាងអឺរ៉ុប កំជាប់ពាក្យគឺជាដំណាក់កាលនៃការប្រកាសអាពាហ៍ពិពាហ៍សាកល្បងនេះមិនមានកំណត់នៅក្នុងច្បាប់ឡើយ គ្រាន់តែពេលខ្លះដំណាក់កាលនៃការសិក្សាពីគ្នាទៅវិញទៅមកនេះអាចឈានទៅដល់ភាពមានបុត្រធីតាថែមទៀត។

### ១.១.១.ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ គឺសេចក្តីសន្យារវាងបុរសនិងនារីថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគតនិងដោយធ្វើពិធីកំជាប់ពាក្យ។[1]

តាមទម្លាប់នៅប្រទេសកម្ពុជា ក្រៅពីការសន្យារវាងគូភាគីនៃកំជាប់ពាក្យ ពិធីសង្គមចាស់ចាត់ទុកថាជាការចាំបាច់សម្រាប់គូភាគីនៃកំជាប់ពាក្យ ពិធីលើកស្លាក៏ជាលក្ខខណ្ឌចាំបាច់ដែរដើម្បីបង្កើតកំជាប់ពាក្យ។ បញ្ញត្តិនេះចែងយ៉ាងច្បាស់ថា កំជាប់ពាក្យនឹងមានអនុភាពដរាបណាភាគីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគតដោយធ្វើកំជាប់ពាក្យ។

#### ១.១.១.១. ការព្រមព្រៀងរបស់គូភាគី

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ពីអាយុរបស់អ្នកដែលអាចធ្វើពិធីកំជាប់ពាក្យទេ។ នេះមានន័យថា អាយុប៉ុន្មានក៏អាចរៀបចំធ្វើពិធីកំជាប់ពាក្យបានដែរ ឲ្យតែអាចផ្តល់ការព្រមព្រៀងបាន។ ហេតុដូច្នេះ ប្រសិនបើជាអនីតិជនគឺចាំបាច់ត្រូវតែមានការយល់ព្រម ឬការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណា

---

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៤

ព្យាបាលសម្រាប់អនីតិជនជាមុនសិនទើបបាន។ ក្នុងន័យនេះ គឺគួរគប្បីកំណត់អាយុយ៉ាងហោចណាស់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅពីព្រោះថាជាអាយុដែលច្បាប់បានកំណត់ថា អាចទទួលខុសត្រូវរដ្ឋប្បវេណីបានស្របតាមមាត្រា ៧៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

**១.១.១.២ ពិធីកំជាប់ពាក្យ**

ពិធីកំជាប់ពាក្យ ឬហៅតាមភាសាសាមញ្ញថាពិធីភ្ជាប់ពាក្យ ត្រូវរៀបចំធ្វើតាមរបៀបយ៉ាងដូចម្ដេចនោះគឺអាស្រ័យទៅតាមប្រពៃណីទំនៀមទំលាប់ និងការជ្រើសរើសរបស់គូភាគីផ្ទាល់តែប៉ុណ្ណោះ។ តាមប្រពៃណីខ្មែរពីបុរាណ នៅមុនការរៀបអាពាហ៍ពិពាហ៍មានការធ្វើពិធីជាច្រើនដូចជា ៖

- **ពិធីចែចូវ**

តាមប្រពៃណីខ្មែរ នៅមុនពេលរៀបអាពាហ៍ពិពាហ៍មានពិធីជាច្រើន ដែលក្នុងនោះមានពិធីចែចូវ ពិធីស៊ីដណ្ដឹង ពិធីស៊ីស្លាកំណត់ជាដើម។ មុននឹងឈានចូលទៅដល់ជីវិតអាពាហ៍ពិពាហ៍ គេតែងតែប្រារព្ធពិធីចែចូវមុនដំបូងគេ នេះបើតាមលក្ខណៈប្រពៃណីខ្មែរ។

ពិធីចែចូវគឺជាពិធីដែលប្រពៃណីមួយដែល គេតែងតែប្រារព្ធនៅពេលមានការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទំលាប់ខ្មែរ ដែលប្រជាជនខ្មែរបានអនុវត្តជាយូរយារណាស់មកហើយ។ ពិធីចែចូវ គឺជាពិធីមួយដែលគេតែងតែប្រារព្ធនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ដែលពិធីនោះធ្វើឡើងដើម្បីសើបសួរកូនស្រីឲ្យមេបាខាងប្រុសបានដឹង ។

ដំបូងបង្អស់ឪពុកម្ដាយ ឬអាណាព្យាបាលខាងប្រុស បានចាត់ស្រីម្នាក់ដែលស្គាល់ទុកចិត្ត មិនអភ័ព្វគូហើយធ្លាប់សិទ្ធិស្នាលនឹងគ្រួសារខាងស្រី អោយទៅស៊ើបការកូនស្រី។ លុះបានដំណឹងថា នាងនៅទំនេរហើយដឹងថ្ងៃខែឆ្នាំកំណើតត្រូវគ្នាល្អ ទើបគេចូលទៅចែចូវដល់ឪពុកម្ដាយ ឬអាណាព្យាបាលរបស់កូនស្រីនោះ។ ឯពិធិចែចូវត្រូវប្រព្រឹត្តិអស់ទៅ៣លើក។ ក្នុងមួយលើកៗ ត្រូវមានស្លាម្លូ ថ្នាំ កំដដៃទៅជាមួយផង។ ក្នុងការចែចូវគេពុំនិយាយគ្នា ត្រង់ៗទេ គឺនិយាយបញ្ចិតបញ្ចៀង។ នៅលើកទី៣ កាលបើខាងស្រីបើកផ្លូវឲ្យដើរ ជណ្ដើរឲ្យឡើងហើយ អ្នកចែចូវក៏ត្រឡប់យកពត៏មានមកប្រាប់ខាងប្រុសវិញ។ ពិធីចែចូវនៅជើងទី៣ នេះគេហៅថា **ស៊ីស្លាដក់**។[2]

- **ពិធីដណ្ដឹង**

ក្រោយពីចាត់មនុស្សឲ្យទៅនិយាយចែចូវបានដឹងថាគេបើកផ្លូវឲ្យចូលហើយ ខាងប្រុសត្រូវរៀបចំគិតគូររឿងស្ដីដណ្ដឹងតទៅទៀត។ មុននឹងចូលថ្ងៃណាៗ ត្រូវឲ្យពត័មានទៅខាងស្រីជាមុនសិន។ ពិធីដណ្ដឹងត្រូវប្រព្រឹត្តិ

---

[2] អ្នកស្រី ត្រឹង ងា , អរិយធម៌ខ្មែរ (១៩៧៤) , ១៧៨

ទៅ៣ដងដែរ។ មនុស្សដែលមានភារៈទៅដណ្ដឹងកូនស្រីគេ ហៅថា អ្នកផ្លូវ ចៅមហា ឯអ្នកតំណាងគ្រួសារខាងស្រី គេឲ្យឈ្មោះថា មេបា។

• លើកទី១ នៅថ្ងៃដែលបានកំណត់ទុក មនុស្សស្រី៣នាក់ដែលមានគូស្រករសុខនឹងគ្នា ត្រូវខាងប្រុសពឹងឲ្យធ្វើជាអ្នកផ្លូវទៅដណ្ដឹងដោយមានថង់រង ១គូ ស្លា ថ្នាំ ឬស្លាធ្វា ចេកទុំ នំអន្សម នំគម នំបត់ រៀបជាគូៗទៅជូនខាងស្រីផង ។ លើកនេះមេបាខាងស្រីពុំទាន់បានសម្រេចអ្វីទេថាចាំពិគ្រោះគ្នាសិន។

• លើកទី២ ដោយនៅលើកទី១ពុំទាន់បានសម្រេច គេឲ្យអ្នកផ្លូវ ៣នាក់ ទៅដណ្ដឹងជាលើកទី២ទៀតដោយមានថង់រង១គូ មានកន្សែងប្របុចក្រាលពីលើ មានស្លា ម្លូ ស្លាធ្វា ទៀន ១គូ ស្រា ១ដប ចេកទុំ នំអន្សម នំគម នំបត់ នំបង់ខ្លាញ់។ ខាងស្រីមិនទាន់សំរេចទៀតថាចង់ឲ្យអ្នកផ្លូវប្រុសៗមកម្ដងវិញ ព្រោះក្រែងអ្នកផ្លូវស្រីៗទទួលបានការគ្រប់ចំពូកមិនបានម្យ៉ាងទៀតចង់ឲ្យនាំកូនប្រុសមកមើលផង។ពិធីនេះហៅថាស៊ីស្លាកន្សែង ។

• លើកទី៣ លើកនេះគេឲ្យស្រី៣នាក់ (អ្នកផ្លូវ) ប្រុស ៣នាក់(អ្នកមហា) ឲ្យនាំរណ្ដាប់ដែលមានថង់រង១គូ ស្លា ម្លូ ថ្នាំ ស្លាធ្វា ទៀនស្រា ចេកទុំ នំអន្សម នំគម នំបត់ នំបត់ខ្លាញ់ នំកន្ត្រំ នំក្រូច អង្ករ ត្រី សាច់ បន្លែ និងផ្លែឈើផ្សេងៗ ជាគូៗ ព្រមទាំងគ្រឿងមាស ពេជ្រ និងសំលៀកបំពាក់ទៅជូនខាងស្រីហើយនាំកូនប្រុសទៅជាមួយផង។ ក្រោយពីសន្ទនារវាងអ្នកផ្លូវ ចៅមហានិងមេបារួចសព្វគ្រប់ មេបាខាងស្រីសុំពិនិត្យសាមីខ្លួនប្រុសព្រមទាំងបញ្ជាក់សួរពីគំនិតមារយាទសាមីខ្លួនប្រុសនោះផង។ ចំណែកឯអ្នកផ្លូវចៅមហា ក៏អាចសុំមើលសាមីខ្លួនស្រីវិញដែរ។ នៅពេលនោះ សាមីខ្លួនស្រីក៏ចេញមកជម្រាបសួរភ្ញៀវ ហើយជួនកាលមានពិធីបំពាក់ចិញ្ចៀនទៅវិញទៅមករវាងគូដណ្ដឹងផង។ នៅតំបន់ខ្លះ ពិធីបំពាក់ចិញ្ចៀននេះ គឺជាពិធីហៅព្រលឹងមួយបែបដែរ។ បន្ទាប់មកអ្នកមហាក៏លើកគ្រឿងស្លាបញ្ជាប់ពាក្យ ជូនទៅមេបាស្រីពិសា។ ពិធីនេះហៅថា ស៊ីស្លាបញ្ជាប់ពាក្យ។

ដោយមេបា ខាងស្រីនៅមិនទាន់អស់ចិត្តអំពីគំនិតមារយាទរបស់សាមីខ្លួនប្រុសទើបមានទំនាមថា ត្រូវឲ្យសាមីខ្លួនប្រុសមកបំរើអនាគតឪពុកម្ដាយក្មេករហូតដល់ពេលរៀបការ ប៉ុន្តែធ្វើតែកិច្ចការនៅក្រៅផ្ទះ គឺពុំទាន់មានសិទ្ធិចូលទៅនៅក្នុងផ្ទះបាននៅឡើយទេ។ ចំណែកទំនាក់ទំនងរវាងគូដណ្ដឹង ក៏ត្រូវគោរពច្បាប់យ៉ាងតឹងរឹង។[3]

➢ **ពិធីជូនកំណត់**

ចំពោះថ្ងៃ ខែរៀបមង្គលការ ដែលគេបានជ្រើសរើសនិងគន់គូរដោយម៉ត់ចត់ហើយ ( គេពុំរើសខែណាដែលមាន២៩ថ្ងៃ ឬខែដែលព្រះសង្ឃចូលវស្សាទេ) ត្រូវយកទៅចុះក្នុងផែនក្រដាសមួយសន្លឹក ហើយត្រូវរៀបចំរៀបរណ្ដាប់កំដរដៃផង មាន ស្លា ម្លូ ចេកទុំ រងស្លា ដែលដាក់គ្រឿងគ្រប់សព្វ។

[3] អ្នកស្រី ត្រឹង ងា , អរិយធម៌ខ្មែរ (១៩៧៤) , ១៨០

រួចហើយអ្នកផ្លូវត្រូវយកក្រដាសកំណត់ពេលា និងរណ្តាប់ទៅជូនមេបាខាងស្រី។ មេបាខាងស្រី ក៏បើកក្រដាសកំណត់ពេលានោះអានជូនភ្ញៀវស្តាប់។ ក្រោយពីបានជូនក្រដាសកំណត់ពេលាទៅមេបារួចហើយអ្នកផ្លូវក៏ជូនស្លាកំណត់ទៅមេបាពិសា។ ពិធីនេះហៅថា **ស៊ីស្លាកំណត់** ។

នៅតំបន់ខ្លះ គេសន្មតយកស្លាថង់រង ឬស្លាកំណត់ទុកជាការសំគាល់ថាបានរៀបការពាក់កណ្តាលដែរ ហើយប្រសិនបើនៅពេលដែលមានអសន្តិសុខនៅក្នុងស្រុក គេគ្រាន់តែរៀបផ្សំផ្គុំកូនប្រុស កូនស្រីនោះដោយសែនប្រាប់ដូនតាជាការស្រេច គឺពុំចាំបាច់ធ្វើពិធីធំដុំទៀតទេ។

នៅទីបញ្ចប់ អ្នកផ្លូវសុំអោយមេបាបង្គាប់នូវគ្រឿងបណ្ដាការសព្វសារពើដែលត្រូវជូន និងប្រើប្រាស់ក្នុងឱកាស ធ្វើមង្គលការ។

ចាប់ពីពេលនេះតទៅ សាមីខ្លួនប្រុសអាចជួយធ្វើការងារនៅក្នុងផ្ទះអនាគតឪពុកម្ដាយក្មេកឬអាណាព្យាបាលបាន។ ចំណែកឯសាមីខ្លួនស្រីជាអ្នករៀបចំដំណេកនិងបាយទឹកឲ្យ ហើយកាលណាមានជម្ងឺនាងនោះមានសិទ្ធិជួយមើលថែទាំថែមទៀត។[4]

## ១.១.២. អនុភាពនៃកំជាប់ពាក្យ

កំជាប់ពាក្យ គឺជាសេចក្តីសន្យា បុរស និងនារី ថានឹងរៀបអាពាហ៍ពិពាហ៍នឹងគ្នានាពេលអនាគត។

ទោះបីជាក្រមរដ្ឋប្បវេណី មិនបានតម្រូវឲ្យមានកំជាប់ពាក្យនៅមុនការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ក៏ដោយ ក៏វាត្រូវមានអនុភាពតាមផ្លូវច្បាប់នៅពេលដែលកំជាប់ពាក្យនោះត្រូវបានធ្វើឡើងនៅមុនពេលដែលរៀបអាពាហ៍ពិពាហ៍។

### ១.១.២.១ ការទទួលខុសត្រូវនៅពេលផ្ដាច់កំជាប់ពាក្យ

ជាទំលាប់ នៅពេលដែលមានពិធីកំជាប់ពាក្យ គឺតែងតែមានការជូនជំនូនអាចភាគីខាងប្រុសជាអ្នកជូន ឬភាគីខាងស្រីជាអ្នកជូនដែរ។ ជំនូននៅទីនេះ អាចជាប្រាក់កាសនិងជាទ្រព្យផ្សេងៗ។ កំជាប់ពាក្យត្រូវបានបង្កើត ក៏ប៉ុន្តែដោយសារហេតុផលអ្វីមួយធ្វើឲ្យកំជាប់ពាក្យត្រូវរំលាយទៅវិញ។

#### ក. ការទាមទារឲ្យសងជំនូន

ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថាខ្លួននឹងបានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែកំជាប់បានរលាយទៅវិញ ភាគីនោះអាចទាមទារឲ្យភាគីម្ខាងទៀតសងជំនូនមកឲ្យវិញបាន។ តាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីនោះ ទោះបីជាភាគីដែលលើកជំនូនមានកំហុស ឬគ្មានកំហុសក្នុងការរំលាយកំជាប់ពាក្យក៏ដោយ ក៏ភាគីនោះអាចទាមទារឲ្យភាគីម្ខាងទៀតសងជំនូនមកវិញបានដែរ។[5]

[4] អ្នកស្រី ត្រឹង ងា , អរិយធម៌ខ្មែរ (១៩៧៤) , ១៨១

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៥

**ខ. ការទាមទារសំណងនៃការខូចខាត**

កំជាប់ពាក្យ គឺជាដំណើរសង្គមដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយមានអត្ថន័យតាមផ្លូវច្បាប់លើសពីអ្វី ដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ហេតុដូចនេះ បើចេះតែឲ្យភាគីអាចរំលាយកំជាប់ពាក្យបានដោយសេរី ទោះបីបើភាគីដែលសុំរំលាយមានកំហុសនោះ វាអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងទំនៀមទំលាប់ល្អនៅក្នុងសង្គម ដូចនេះ ទើបក្រមរដ្ឋប្បវេណីដាក់កំរិតចំពោះភាគីដែលមានកំហុសក្នុងការរំលាយកំជាប់ពាក្យត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត។ វាមានន័យថា បើភាគីម្ខាងបដិសេធដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការបដិសេធចោលនោះដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ឬអំពើអនីត្យានុកូល។[6]

**គ. ភស្តុតាងនៃកំជាប់ពាក្យ**

ដោយសារតែកំជាប់ពាក្យគ្រាន់តែជាការសន្យានោះ នាំឲ្យពុំមានលិខិតស្នាមបញ្ជាក់នៃការកំជាប់ពាក្យ ដូច្នេះភាគីនៃកំជាប់ពាក្យអាចប្រើប្រាស់នូវលទ្ធភាពរបស់ខ្លួនគ្រប់មធ្យោបាយដើម្បីបង្ហាញភស្តុតាង។[7]

**ឃ. ភស្តុតាងនៃកំហុស**

ក្នុងដែនអនុវត្តនៃក្របខណ្ឌនៃនីតិរួម ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញឲ្យឃើញនូវកំហុសរបស់ភាគីចុងចម្លើយនៃគូក្តី។ ដូច្នេះ មានការបកស្រាយលើប្រភពដើមនៃកំជាប់ពាក្យ វាជាកិច្ចសន្យាដែលចាប់បង្ខំឲ្យភាគីចង់ដកខ្លួនចេញពីកិច្ចសន្យានោះ បង្ហាញហេតុផលពិតបើគ្រាន់តែជាព្រឹត្តិការណ៍សាមញ្ញនេះមិនអាចកើតមានអនុភាពលើការផ្តាច់បានឡើយ ពីព្រោះត សច្ចធារណ៍នៃកំហុសលើការផ្តាច់ពាក្យពុំអាចកើតមានបាន មានន័យថាកំហុសត្រូវតែបង្ហាញ គ្មានកំហុស គ្មានការផ្តាច់ពាក្យ បើគ្មានការផ្តាច់ពាក្យ នោះនឹងនាំឲ្យគ្មានកំហុស។[8]

**ង. អំឡុងពេលទាមទារ**

ការទាមទារឲ្យសងជំនូន និងការទាមទារសំណងនៃការខូចខាត អ្នកមានបំណងទាមទារត្រូវដាក់ពាក្យបណ្តឹងទៅតុលាការក្នុងអំឡុងពេល១ឆ្នាំចាប់ពីកំជាប់ពាក្យបានរលាយ។[9]

ឧទាហរណ៍ ៖ លោក សម័យ បានភ្ជាប់ពាក្យជាមួយនឹងកញ្ញា ចិន្តា ដោយបានជូនម៉ូតូមួយគ្រឿងជាជំនូននៅក្នុងពិធីភ្ជាប់ពាក្យ។ បន្ទាប់ពីកំជាប់ពាក្យបានរយៈពេល ៣ខែ ស្រាប់តែ កញ្ញា ចិន្តា បានដឹងថាលោក សម័យមានភរិយាហើយ ពួកគេទាំងពីរនាក់បានឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងរហូតដល់ការព្រមព្រៀងគ្នារលាយកំជាប់ពាក្យ។ ក្រោយពីរលាយកំជាប់ពាក្យលោក សម័យ បានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារជំនូនមក

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៦
[7] ស្រី វណ្ណធី, នីតិបេតិកភណ្ឌគ្រួសារ (២០១២), ១៨
[8] ស្រី វណ្ណធី, នីតិបេតិកភណ្ឌគ្រួសារ (២០១២), ២២
[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៧

វិញ និងកញ្ញា ចិន្តា ក៏បានដាក់ពាក្យប្តឹងទាមទារសំណងខូចខាតពីលោក សម័យ ដែរ។ ពួកគេមានអំឡុងពេលមួយខែនៅក្នុងការទាមទារជំនួន និងសំណងនៃការខូចខាត គិតចាប់ពីថ្ងៃកំជាប់ពាក្យបានរលាយ។

**១.១.២.២. អនុភាពចំពោះបុគ្គភាពដែលកើតចេញពីកំជាប់ពាក្យ**

ករណីបែបនេះនៅប្រទេសយើងពុំទាន់ ឬកម្រកើតមានដោយយោងទៅលើគោលការណ៍ប្រពៃណីទំនៀមទំលាប់។ ការវិភាគនៅក្នុងក្របខណ្ឌច្បាប់ បុត្តភាពដែលមានក្នុងអំឡុងពេលនៃកំជាប់ពាក្យត្រូវបានផ្តាច់ស្ថិតក្រោមអនុភាពនៃនីតិរូម ដោយយោងតាមអាពាហ៍ពិពាហ៍ពុំទាន់កើតមានជាផ្លូវការនៅឡើយ ដូច្នេះវានឹងចាត់ចូលទៅក្នុងប្រភេទបុត្តភាពគ្មានខាន់ស្លាដែរ។ ចំណុចនេះមានបញ្ហាពីរយ៉ាងដែលត្រូវធ្វើការពិភាក្សា ទីមួយទៅលើភាគីជាមាតានឹងទទួលបានសំណងជម្ងឺចិត្តដែលជាសំណងលើព្យសនកម្មផ្ទាល់ខ្លួន លទ្ធផលនៃការផ្តាច់ បញ្ហាទីពីរ គឺបុត្តភាពនឹងមិនទទួលសំណងជម្ងឺចិត្តដូចមាតាខ្លួនទេ តែផ្ទុយទៅវិញគឺការទាមទារការអនុវត្តន៍កាតព្វកិច្ច និងការផ្គត់ផ្គង់ខាងផ្នែកស្មារតី និងសម្ភារៈ។[10]

## ១.២ កំជាប់ពាក្យថៃ

ប្រពៃណីទំនៀមទំលាប់នៃប្រទេសថៃ ក៏មិនសូវមានភាពខុសគ្នាប៉ុន្មានដែរទៅនឹងប្រទេសកម្ពុជាដែរ។ តាមប្រពៃណីនៃប្រទេសថៃ មុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍គឺគេតែងតែមានការប្រារព្ធពិធីកំជាប់ពាក្យ។ នៅក្នុងគ្រួសារដែលមានជីវភាពសមរម្យ គេតែងតែប្រារព្ធពិធីនេះមានលក្ខណៈអធិកអធមដូចគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍ដែរ។ នៅក្នុងពិធីកំជាប់ពាក្យគេតែងតែមានការបំពាក់ចិញ្ចៀនគ្នាទៅវិញទៅមក ឬក៏ការប្រគល់នូវវត្ថុអនុស្សាវរីយ៍ផ្សេងៗទៅតាមសមត្ថភាពនិងធនធានរបស់ពួកគេ។

ផ្អែកតាមក្រមរដ្ឋប្បវេណីនៃប្រទេសថៃ គឺមិនមាននូវការឲ្យនិយមន័យជាក់លាក់ណាមួយនៃកំជាប់ពាក្យនោះទេ ពោលគឺមានតែកំណត់លក្ខខណ្ឌនានានៃកំជាប់ពាក្យ។

**១.២.១. ការបង្កើតកំជាប់ពាក្យ**

**១.២.១.១ លក្ខខណ្ឌអាយុនៃកំជាប់ពាក្យ**

កំជាប់ពាក្យ គឺជាប្រពៃណីនៃប្រទេសថៃដែលត្រូវបានប្រជាជនថៃបានអនុវត្តតៗគ្នាតាំងពីបុរាណមក។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ បានកំណត់អាយុភាគីនៅក្នុងការព្រមព្រៀងគ្នាដើម្បីឲ្យការធ្វើកំជាប់ពាក្យមួយប្រព្រឹត្តិទៅតាមច្បាប់កំណត់។ នៅក្រមរដ្ឋប្បវេណីថៃ កំជាប់ពាក្យមួយអាចធ្វើទៅបានលុះត្រាតែបុរសនិងនារីមានអាយុចាប់ពី ១៧ ឆ្នាំឡើងទៅ។ កំជាប់ពាក្យដែលបានធ្វើឡើងដោយភាគីមិនទាន់ដល់អាយុ ១៧ ឆ្នាំ ត្រូវចាត់ទុកជាមោឃៈ។[11]

[10] ស្រី វណ្ណធី, នីតិបេតិកភណ្ឌគ្រួសារ (២០១២), ២៣

[11] **Thai Civil and Commercial Code , Section 1435**

ប្រសិនបើនៅក្នុងកំជាប់ពាក្យ មានភាគីជាអនីតិជន អនីតិជននោះត្រូវតែមានការយល់ព្រមពីអ្នកមានអំណាចមេបា ឪពុកម្ដាយចិញ្ចឹមក្នុងករណីដែលអនីតិជនគឺជាកូនសុំ និងអ្នកអាណាព្យាបាលរបស់អនីតិជន។ កំជាប់ពាក្យដែលបានធ្វើឡើងដោយគ្មានយល់ព្រមពីអនីតិជនផ្ទាល់ខ្លួនទេ ត្រូវចាត់ជាមោឃៈ។[12]

**១.២.១.២ ការធ្វើពិធីកំជាប់ពាក្យ**

ទោះបីជាភាគីពេញវ័យនីតិភាពនៅក្នុងការធ្វើកំជាប់ពាក្យក៏ដោយ ក៏កំជាប់ពាក្យពុំទាន់មានសុពលភាពទៅតាមផ្លូវច្បាប់នោះទេ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃបានបញ្ញត្តិ កំជាប់ពាក្យមួយអាចមានសុពលភាពទៅបាននៅពេលដែលភាគីខាងប្រុសនិងភាគីខាងស្រីបានធ្វើពិធិកំជាប់ពាក្យ និងភាគីខាងប្រុសបានប្រគល់អំណោយទៅភាគីខាងស្រី និងបណ្ណាការទៅមេបាខាងស្រី។ ក្រោយពីកំជាប់ពាក្យរួច អំណោយដែលភាគីខាងប្រុសបានប្រគល់ទៅខាងស្រី នឹងក្លាយជាកម្មសិទ្ធិខាងស្រី។

តាមប្រពៃណីទំនៀមទំលាប់នៃប្រទេសថៃ នៅពេលមានពិធីកំជាប់ពាក្យ គេតែងតែមានពិធីជាច្រើនដូចជា៖

- **ពិធី Khan Maak** ขันหมาก

ពិធី Khan Maak ขันหมาก គឺជាពិធីហែហមភាគីខាងប្រុសទៅមុខផ្ទះភាគីខាងស្រី។ ការដង្ហែក្បួននេះមានការចូលរួមពីសំណាក់ភាគីខាងប្រុស អ្នកតំណាងខាងប្រុស ឪពុកម្ដាយខាងប្រុស សាច់ញាតិ និងមិត្តភក្ដិជិតឆ្ងាយនៃភាគីខាងប្រុស។ នៅពេលធ្វើដំណើរទៅមុខផ្ទះភាគីខាងស្រី ក្នុងដៃកូនប្រុសមានកាន់ផ្កា ធូប ទៀន និងជំនូន ដែលក្បួនដង្ហែអមទៅដោយអ្នកវាយស្គរ អ្នករាំរបាំបុរាណប្រពៃណី ដែលពួកគេជាអ្នកស្រែកប្រកាសអំពីដំណើរមកនៃខាងប្រុសមកដល់មុខផ្ទះខាងស្រី។

- **ពិធីឃាំងកូនប្រុស**

ដើម្បីអាចឲ្យពិធីប្រព្រឹត្តិទៅទៀតបាន ភាគីខាងប្រុសត្រូវនាំភាគីខាងស្រីពីក្នុងគេហដ្ឋានដើម្បីធ្វើពិធីកំជាប់ពាក្យ។ ប៉ុន្តែដើម្បីអាចនាំកូនក្រមុំមកធ្វើពិធីកំជាប់បាន ភាគីខាងប្រុសត្រូវតែជម្នះឧបសគ្គនៅតាមផ្លូវចូលទៅនាំ ភាគីខាងស្រីដែលរៀបចំដោយគ្រួសារភាគីខាងស្រីដែលក្នុងនោះមានមនុស្សស្រីពីរនាក់ កាន់ខ្សែឃាំងជារបងដើម្បីឃាំងភាគីខាងប្រុសមុននឹងចូលទៅនាំភាគីខាងស្រីមកភ្ជាប់ពាក្យ។ ជាធម្មតា មានការកាន់ខ្សែឃាំងជារបងដើម្បីឃាំងភាគីខាងប្រុសចំនួន ៣កន្លែង ឬលើសពីនេះ ដែលការឃាំងនីមួយអាចជារបងមាស ឬរបងប្រាក់អាស្រ័យទៅនឹងសំលៀកបំពាក់និងគ្រឿងអលង្ការនៃអ្នកកាន់ខ្សែឃាំង។

[12] **Thai Civil and Commercial Code , Section 1436**

នៅពេលមកដល់កន្លែងឧបសគ្គ ភាគីខាងប្រុសអាចត្រូវបានគេសួរសំណួរ ឬពេលខ្លះត្រូវបានគេនិយាយបញ្ឆោរដើម្បីឲ្យបរិយាកាសប្រកបទៅភាពសិទ្ធិស្នាល និងដើម្បីបញ្ជាក់ថាតើ ភាគីខាងប្រុសឆ្លងផុតឧបសគ្គដែរឬទេ? នៅក្នុងការឆ្លងផុតឧបសគ្គនីមួយៗ គឺអាស្រ័យលើការចរចាជាមួយនឹងមនុស្សពីរនាក់ដែលកាន់ខ្សែឃាំង។ ដោយអាស្រ័យទៅនឹងស្ថានការណ៍ ភាគីខាងប្រុសអាចប្រគល់នូវអាំងប៉ាវជូនមនុស្សដែលកាន់ខ្សែដើម្បីឲ្យដំណើររបស់គេប្រព្រឹត្តិទៅដោយរលូន។

➢ **ពិធីកំជាប់ពាក្យ**

តាមទំនៀមទំលាប់នៃប្រពៃណីថៃ កំជាប់ពាក្យ គឺជាកិច្ចសន្យាដែលបុរសនិងនារីសន្យាថានឹងរៀបអាពាហ៍ពិបាហ៍នឹងគ្នានៅពេលខាងមុខដូចវប្បធម៌បស្ចិមប្រទេសដែរ។ ពិធីកំជាប់ពាក្យ គឺជាពិធីមួយដែលធ្វើឡើងដើម្បីណែនាំកូនស្រីដើម្បីឲ្យស្គាល់កូនប្រុសដែលឪពុកម្ដាយបានផ្សំផ្គុំ និងជាឱកាសមួយដែលធ្វើឲ្យពួកគេស្គាល់ចិត្តស្គាល់ថ្លើមគ្នា មុនពេលឈានចូលដល់ពេលរៀបអាពាហ៍ពិពាហ៍។ នៅពេលបច្ចុប្បន្ន គូស្រករភាគច្រើននៅក្នុងប្រទេសថៃបានជ្រើសរើសដៃគូជីវិតដោយខ្លួនឯងជំនួសដោយការជ្រើសរើសផ្សំផ្គុំពីឪពុកម្ដាយ។

នៅក្នុងពិធីកំជាប់ពាក្យក្រៅពី ការបំពាក់ចិញ្ចៀនគ្នាទៅវិញទៅមក កូនប្រុសអាចប្រគល់គ្រឿងអលង្ការដទៃទៀតឲ្យទៅកូនស្រីបានផងដែរ ដែលធ្វើនៅមុខមេបាទាំងសងខាង។[13]

**១.២.២ អនុភាពនៃកំជាប់ពាក្យ**

កំជាប់ពាក្យ គឺជាកិច្ចសន្យាដែលបុរសនិងនារីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍នៅពេលអនាគត។ នៅពេលដែលភាគីទាំងសងខាងបានបំពេញនូវលក្ខខណ្ឌច្បាប់ ដែលមានចែងនៅក្នុងច្បាប់នោះអនុភាពនៃកំជាប់ពាក្យក៏ចាប់ផ្ដើមកើតមានឡើង។

**១.២.២.១ ការទាមទារសំណង**

**ក.ការទាមទារសំណងក្នុងករណីដែលភាគីបំពានកិច្ចសន្យា**

នៅពេលដែលកំជាប់ពាក្យកំពុងមានសុពលភាព ប្រសិនបើភាគីណាមួយបំពានទៅនឹងកិច្ចសន្យាកំជាប់ពាក្យនោះ ភាគីម្ខាងទៀតធ្វើការអាចទាមទារសំណងពីភាគីដែលបំពានកិច្ចសន្យាបាន។ សំណងដែលភាគីអាចទាមទារបានមានដូចជា ៖

- សំណងនៃការខូចខាតកិត្តិយសនៃភាគីណាមួយ
- សំណងនៃបំណុល ឬការចំណាយដែលភាគីម្ខាងបានចំណាយដោយរំពឹងថាអាពាហ៍ពិពាហ៍នឹងកើតមានឡើង
- ការខូចខាតដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិឬការងារ ដែលរំពឹងទុកពីការរៀបអាពាហ៍ពិពាហ៍

[13] Learnthaiwithmod.com/2013/09/thai-tradition-wedding-ceremony/

នៅក្នុងករណីដែល ភាគីខាងនារីមានសិទ្ធិទទួលបានសំណង តុលាការអាចសម្រេចថាជំនូនដែលខាងបុរសបានជូនទៅខាងនារីគឺជាសំណងទាំងមូលឬមួយផ្នែកនៃសំណង។ តុលាការក៏អាចសម្រេចបង្គាប់ឲ្យភាគីខាងបុរសបង់ប្រាក់សំណងដោយមិនគិតពីជំនូនដែលបានជូន។[14]

**ខ.ការទាមទារសំណងពីតតិយជន**

នៅក្នុងករណីដែលតតិយជន បានប្រព្រឹត្តអំពើល្មើសរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើភាគីខាងនារី ដែលធ្វើកំជាប់ពាក្យដែលមិនអាចប្រព្រឹត្តទៅបាន ភាគីខាងបុរសអាចទាមទារសំណងការខូចខាតពីតតិយជននោះបាន។[15]

**១.២.២.២ ការទាមទារជំនូន**

នៅក្នុងករណីដែលមានមូលហេតុពិសេសដែលមិនអាចឲ្យអាពាហ៍ពិពាហ៍កើតឡើង ភាគីអាចទាមទារជំនូនមកវិញបាន។ នៅពេលដែលមូលហេតុកើតឡើងទៅលើនារី ដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន ភាគីខាងនារីត្រូវប្រគល់ជំនូនទៅភាគីខាងបុរសវិញ។[16] ប្រសិនបើមូលហេតុបានកើតឡើងទៅលើបុរសវិញ ដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន ភាគីខាងបុរសមិនអាចទាមទារជំនូនពីខាងនារីមកវិញបានទេ។[17]

**១.២.២.៣ អំឡុងពេលទាមទារ**

នៅក្នុងការទាមទារសំណងនៃការខូចខាតនិងការទាមទារជំនូន ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការក្នុងរយៈពេល ៦ខែ គិតចាប់ពីពេលដែលភាគីម្ខាងបានបំពានទៅនឹងកិច្ចសន្យាកំជាប់ពាក្យ ឬមានមូលហេតុពិសេសណាមួយបានកើតឡើង។[18] រីឯការទាមទារសំណងនៃការខូតខាតពីតតិយជនវិញ ភាគីអាចដាក់ពាក្យបណ្តឹងទៅតុលាការក្នុងអំឡុងពេល ៦ខែ ចាប់តាំងពីពេលដែលខ្លួនបានដឹងពីអំពើល្មើស ប៉ុន្តែមិនឲ្យហួសពី ៥ ឆ្នាំ គិតចាប់ពីបទល្មើសដែលបានកើតឡើង។[19]

[14] Thai Civil and Commercial Code , Section 1440
[15] Thai Civil and Commercial Code , Section 1445
[16] Thai Civil and Commercial Code , Section 1442
[17] Thai Civil and Commercial Code , Section 1443
[18] Thai Civil and Commercial Code , Section 1447(2)
[19] Thai Civil and Commercial Code , Section 1447(1)

# ជំពូកទី២ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងខ្មែរ

នៅក្នុងសង្គមខ្មែរ ពិធីរៀបមង្គលការជាប្រពៃណីមួយដែលមានបញ្ញត្តិប្រហាក់ប្រហែលគ្នានឹងកាតព្វកិច្ចដែរ ព្រោះអ្នកដែលយកគ្នាជាប្តីប្រពន្ធត្រូវតែរៀបការ បើគេចវេះពិធីនេះ នឹងត្រូវចាត់ទុកជាអ្នកគ្មានសិរីសួស្តី និងគ្មានកិត្តិយស ។

ខ្មែរប្រើពាក្យ អាពាហ៍ពិពាហ៍ ឬ អាវាហ៍វិវាហ៍ គឺជាមង្គលការគូប្រុសស្រីដែលនាំគ្នាមក ហើយត្រឡប់ទៅវិញ (ពីរលើក) ។ ប៉ុន្តែតាមប្រពៃណីខ្មែរ គេនាំកូនប្រុសមកខាងលំនៅខាងកូនស្រីមុន ហើយនាំកូនស្រីទៅរោងខាងប្រុសវិញ។ ប៉ុន្តែទោះបីគេធ្វើត្រឹមតែនាំកូនប្រុសមកលំនៅខាងកូនស្រីតែម្យ៉ាង ក៏គេនិយមហៅគួបទាំងពីរយ៉ាងថាអាពាហ៍ពិពាហ៍ដែរ។[20]

## ២.១ លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយមានអនុភាពតាមផ្លូវច្បាប់ ក្រមរដ្ឋប្បវេណីបានកំណត់នូវលក្ខខណ្ឌចាំបាច់មួយចំនួនដែលគូភាគីត្រូវគោរពតាមជាដាច់ខាត។ ជារួមមានលក្ខខណ្ឌចំនួន២ គឺលក្ខខណ្ឌច្បាប់ ឬសារធាតុ និងលក្ខខណ្ឌទម្រង់

### ២.១.១ លក្ខខណ្ឌច្បាប់

លក្ខខណ្ឌច្បាប់ ឬលក្ខខណ្ឌសារធាតុគឺជាលក្ខខណ្ឌមួយដែលធ្វើឲ្យចំណងអាពាហ៍ពិពាហ៍ដែលពលរដ្ឋគ្រប់រូបត្រូវតែគោរពតាមជាដាច់ខាត ព្រោះអាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធភាពជីវិតរវាងបុរសនិងនារី ដូច្នេះបុរសនិងនារីចាំបាច់ត្រូវតែពេញវ័យ ទាំងផ្នែកសេដ្ឋកិច្ច ផ្លូវចិត្ត ផ្លូវកាយហើយវាជាការកំណត់នៅក្នុងច្បាប់។

#### ២.១.១.១. លក្ខខណ្ឌអាយុ

នៅតាមបណ្តាប្រទេសនីមួយៗតែងតែកំណត់នូវអាយុអប្បបរមាមួយដែលអាចសមស្របសម្រាប់ការរៀបអាពាហ៍ពិពាហ៍។ នៅក្នុងប្រទេសកម្ពុជា បានកំណត់យកអាយុសម្រាប់ការរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបានឈានដល់វ័យនីតិភាពជាអាយុអប្បបរមាដែលសមរម្យដែលអាចរៀបអាពាហ៍ពិពាហ៍បាន ដើម្បីឲ្យភាគីនៃអាពាហ៍ពិពាហ៍មានស្មារតីគ្រប់គ្រាន់នៅក្នុងការបង្ហាញឆន្ទៈដើម្បីរៀបអាពាហ៍ពិពាហ៍។

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចែងថា បុរសនិងនារី ដែលមិនទាន់ដល់វ័យនីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[21] នីតិភាពនៅចំណុចនេះជាធម្មតាមានន័យថាបានដល់អាយុ១៨ឆ្នាំ ប៉ុន្តែក៏រួមទាំងបញ្ចូលផងដែរនូវអាយុ ១៦ឆ្នាំ ឬ១៧ឆ្នាំ ដែលទទួលបានអត្តាធីនភាព។[22] ប៉ុន្តែនៅក្នុងករណីដែលភាគី

[20] អ្នកស្រី ត្រឹង ងា , អរិយធម៌ខ្មែរ (១៩៧៤) , ១៧៥

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៨

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១

ម្ខាងបានដល់នីតិភាពហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំអាចធ្វើការរៀបអាពាហ៍ពិពាហ៍បានដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។ នៅក្នុងករណីដែលអ្នកមានអំណាចមេបាមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីអ្នកដែលមានអំណាចមេបាម្ខាង ជាការគ្រប់គ្រាន់។ នៅក្នុងលក្ខខណ្ឌដែលអនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ប៉ុន្តែមិនមានអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ នោះអ្នកអាណាព្យាបាល សម្រាប់អនីតិជនត្រូវបានជ្រើសតាំងជាមុន[23] និងការយល់ព្រមពីអាណាព្យាបាលសម្រាប់អនីតិជនមានភាពចាំបាច់។ ប៉ុន្តែនៅក្នុងករណីដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុ អនីតិជនដែលមានចំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន។

**២.១.១.២.លក្ខខណ្ឌទ្វេពន្ធភាព**

ព្រះរាជាណាចក្រកម្ពុជាបានអនុម័តប្រកាន់យករបបឯកពន្ធភាព បុរសត្រូវបានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនារីលើសពីមួយនាក់ ហើយនារីក៏មិនអាចរៀបអាពាហ៍ជាមួយបុរស លើសពីម្នាក់បានដូចគ្នា។ ក្រមរដ្ឋប្បវេណីចែងថា បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។[24]

ទ្វេពន្ធភាពមានន័យថា ការរៀបអាពាហ៍ពិពាហ៍ពីរស្របច្បាប់។ ចំពោះការរៀបអាពាហ៍ពិពាហ៍មួយស្របច្បាប់ និងមួយទៀតជាការរួមរស់បែបអនីតិសង្វាស នោះមិនត្រូវបានចាត់ទុកជាទ្វេពន្ធភាព។

ប្រសិនបើបុគ្គលម្នាក់ត្រូវបានប្រកាសអំពីការបាត់ខ្លួន នោះបុគ្គលនោះត្រូវបានចាត់ទុកជាបានទទួលមរណភាព។ ដូច្នេះ សហព័ទ្ធរបស់បុគ្គលដែលបានបាត់ខ្លួនអាចរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយបុគ្គលម្នាក់ទៀត។ ប្រសិនបើបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ថ្មី បុគ្គលដែលបានបាត់ខ្លួននោះបានត្រឡប់មកវិញ ហើយការប្រកាសអំពីបាត់ខ្លួនត្រូវបានលុបចោល តើយើងត្រូវចាត់ទុកអាពាហ៍ពិពាហ៍ទាំងពីរនេះយ៉ាងដូចម្តេច? ចំពោះករណីនេះ អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយនៅពេលដែលអាពាហ៍ពិពាហ៍ថ្មី ហើយមានតែអាពាហ៍ពិពាហ៍ក្រោយទេដែលមានអនុភាព។[25]ជនដែលបានប្រព្រឹត្តិល្មើសពាក់ព័ន្ធទៅនឹងឯកពន្ធភាពត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែដល់ ១(មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ ១០០.០០០ (មួយរយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ។[26]

---

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៦៨

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៩

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤

[26] ច្បាប់ស្តីពីឯកពន្ធភាព , មាត្រា ៩

### ២.១.១.៣. លក្ខខណ្ឌវិធវភាព

គោលការណ៍វិធវភាព គឺជាគោលការណ៍មួយដែលហាមឃាត់នារីមិនឲ្យរៀបអាពាហ៍ពិពាហ៍ដើម្បីកសាងគ្រួសារថ្មីបន្ទាប់ពីអាពាហ៍ពិពាហ៍ចាស់បានរំលាយ។ គោលការណ៍នេះត្រូវបានបញ្ញត្តិឲ្យដឹងច្បាស់ថាតើកូននៅក្នុងផ្ទៃរបស់ស្ត្រីជាកូនរបស់ប្តីមុន ឬកូនរបស់ប្តីក្រោយ។

ក្រោយពីអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ឬត្រូវបានលុបចោលដោយមូលហេតុប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬការលែងលះគ្នា នារីមិនអាចរៀបអាពាហ៍ពិពាហ៍បានទៀតទេដោយនៅរង់ចាំឲ្យផុតនូវគោលការណ៍វិធវភាពជាមុនសិន ពោលគឺឲ្យមេម៉ាយមួយរយៈសិន។ តាមក្រមរដ្ឋប្បវេណី នារីមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល១២០ ថ្ងៃពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ ប៉ុន្តែករណីខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលហើយបានសម្រាលកូន ឬចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត។[27]

### ២.១.១.៤. ការហាមឃាត់រវាងញាតិពន្ធ

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ ព្រោះការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ និងរវាងជនដែលធ្លាប់ជាញាតិពន្ធខ្សែផ្ទាល់ ដោយសារតែញាតិលោហិតខ្សែផ្ទាល់របស់សហព័ទ្ធមានទំនាក់ទំនងគ្នាប្រហាក់ប្រហែលនឹងញាតិលោហិតដែរ ខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូន ដូច្នេះតាមសីលធម៌សង្គមក៏អាពាហ៍ពិពាហ៍បែបនេះមិនមែនជាគួរដែរ។

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនោះមាននិន្នាការបង្កើតទំនាក់ទំនងញិតជារួម ដែលមានលក្ខណៈជិតស្និទ្ធស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិលោហិតដែរ។ ប៉ុន្តែ ដោយសារតែតាមទំនៀមទំលាប់នៅក្នុងប្រទេសកម្ពុជាមានករណីអាពាហ៍ពិពាហ៍ជាមួយបង ឬប្អូនប្រុស ដែលនៅលីវរបស់សពប្តី ឬករណីដែលប្រពន្ធបានទទួលមរណភាព ហើយប្អូនស្រី ឬបងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ដើម្បីមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពនោះជាដើម ហើយម្យ៉ាងទៀត ការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនរបស់ប្តី និងបងប្អូនបង្កើតរបស់ប្រពន្ធក៏ឃើញមានផងដែរ ដូច្នេះសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធនៅក្នុង៣ថ្នាក់បាន បើតាមក្រមរដ្ឋប្បវេណីមាត្រា ៩៥២ ។[28]

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥០
[28] អាពាហ៍ពិពាហ៍ និង ការលែងលះ , សិក្ខាសាលាគណៈមេធាវីលើកទី៧, ទំព័រ ២៩

### **២.១.១.៥. ការហាមឃាត់ខាងញាតិលោហិត**

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយរវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិត ក្នុង៣ថ្នាក់រាប់ទាំងថ្នាក់ទី៣ផងដែរ នេះបើតាមមាត្រា៩៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតបែបនេះ ត្រូវបានហាមឃាត់ដោយសារការរៀបអាពាហ៍ពិពាហ៍រវាងសាច់ញាតិវាមានលក្ខណៈផ្ទុយនឹងសីលធម៌សង្គម ហើយសង្គមភាគច្រើនក៏មិនទទួលស្គាល់អាពាហ៍ពិពាហ៍បែបនេះដែរ។ ម្យ៉ាងទៀត ការរៀបអាពាហ៍ពិពាហ៍រវាងសាច់ញាតិ លទ្ធភាពនៃពិការភាពរបស់កូនដែលកើតមកមានកំណើនខ្ពស់។[29]

### **២.១.១.៦. លក្ខខណ្ឌទាក់ទងនឹងព្រមព្រៀង**

ជាគោលការណ៍ ការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ ត្រូវតែជាការយល់ព្រមព្រៀងដោយសេរី ពោលគឺមិនត្រូវមានការបង្ខំ ការគំរាម ការឆបោក ឬ ការភ័ន្តច្រឡំលើមុនុស្សឡើយ។ ការបង្ខំ និងការភ័ន្តច្រឡំលើមនុស្សត្រូវបានចាត់ទុកថាជាមូលហេតុនៃមោឃភាពនៃអាពាហ៍ពិពាហ៍។ ការគំរាម និងការឆបោក គឺជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍។

យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីមិនបានផ្តល់និយមន័យឲ្យបានច្បាស់លាស់នៃពាក្យ ការបង្ខំ ការគំរាម ការភ័ន្តច្រឡំលើមនុស្ស និង ការឆបោក ឡើយ។ ប៉ុន្តែ គេអាចកំណត់បានថា ការបង្ខំ គឺចង់សំដៅលើករណីនៃជនដែលត្រូវរៀបអាពាហ៍ពិពាហ៍ ដោយគ្មានសេរីភាពក្នុងការជ្រើសរើសទាល់តែសោះ ពោលគឺ ការបង្ខំបានធ្វើឲ្យសាមីខ្លួនគ្មានឆន្ទៈនឹងរៀបអាពាហ៍ពិពាហ៍តែម្តង។ ទន្ទឹមនឹងនេះ បើតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី ការបង្ខំមានលក្ខណៈខ្លាំងក្លាជាការគំរាម មានន័យថា ការបង្ខំគឺមានលក្ខណៈដាច់ណាត់ជាងការគំរាម ត្រង់ថាការបង្ខំធ្វើឲ្យសាមីខ្លួនគ្មានឆន្ទៈជ្រើសរើស ក៏ប៉ុន្តែសម្រាប់ការគំរាមវិញ សាមីខ្លួនជ្រើសរើសរៀបការ ក៏ព្រោះតែការភ័យខ្លាច។

ចំណែកឯការភ័ន្តច្រឡំលើមនុស្សវិញ គឺសំដៅទៅលើករណីនៃការភ័ន្តច្រឡំទៅលើអត្តសញ្ញាណរបស់មនុស្ស។ល។

លើសពីនេះទៅទៀត ការគំរាម គឺជាមធ្យោបាយខុសច្បាប់មួយ តាមរយៈការជូនដំណឹងពីភាពអាក្រក់ទៅភាគីម្ខាងទៀត ក្នុងគោលដៅឲ្យជននោះមានការភ័យខ្លាច ហើយយល់ព្រមរៀបអាពាហ៍ពិពាហ៍។

ដោយឡែកចំពោះ ការឆបោក គឺជាបោកប្រាស់ឲ្យជនណាម្នាក់ធ្លាក់ទៅក្នុងការភ័ន្តច្រឡំ ហើយយល់ព្រមរៀបការ។[30]

### **២.១.១.៧. លក្ខខណ្ឌទាក់ទងនឹងសមត្ថភាព**

---

[29] អាពាហ៍ពិពាហ៍ និង ការលែងលះ , សិក្ខាសាលាគណៈមេធាវីលើកទី៧, ទំព័រ ២៩

[30] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ (២០១៧), ៣២២

នៅក្នុងករណីណាក៏ដោយ ភាគីនៃអាពាហ៍ពិពាហ៍ត្រូវតែជាមនុស្សមានសមត្ថភាពបង្ហាញឆន្ទៈ។ ក៏ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅ គឺអាចរៀបអាពាហ៍ពិពាហ៍បាន នៅក្នុងករណីដែលជននោះអាចមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ (មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី)។ក្នុងករណីបែបនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់ថា មិនចាំបាច់តម្រូវឲ្យមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។

ចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម អាចរៀបអាពាហ៍ពិពាហ៍បានដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថមកៈឡើយ (មាត្រា ៣០នៃក្រមរដ្ឋប្បវេណី មិនតម្រូវឲ្យធ្វើបែបនេះទេ)។[31] ដែលខុសពីអនីតិជនដែលចង់រៀបអាពាហ៍ពិពាហ៍ តម្រូវឲ្យមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលតាមច្បាប់កំណត់ដែលជាលក្ខខណ្ឌមិនអាចខ្វះបាន។

### ២.១.២. លក្ខខណ្ឌទម្រង់

តាមធម្មតា លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងពលរដ្ឋខ្មែរតាមបទបញ្ញត្តិនៃច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺអនុលោមតាមមាត្រា៩៥៥ ដល់មាត្រា៩៥៧ នៃក្រមរដ្ឋប្បវេណី និងអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ធ្នូឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២០ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន និងអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។ គួរកត់សម្គាល់ថា បើផ្អែកតាមមាត្រា ៩៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានចែងយ៉ាងច្បាស់ថា ៖ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍ត្រូវធ្វើដោយផ្អែកនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ញត្តិស្តីពីការចុះអត្រានុកូលដ្ឋាន។[32]

#### ២.១.២.១.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ដែលធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបទបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងនៅក្នុងច្បាប់។[33]

---

[31] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ (២០១៧), ៣២០

[32] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ (២០១៧), ៣២៧

[33] ច្បាប់ស្តីពីឯកពន្ធភាព , មាត្រា ៣

បុរស និងនារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់នៃលំនៅដ្ឋានសាមីខ្លួននារី។ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យឲ្យបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[34]

**២.១.២.២. ការប្រកាសជាសាធារណៈ**

បន្ទាប់ពីបុរសនិងនារីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នាបានធ្វើការដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងធ្វើនោះផ្សាយជាសាធារណនៅលំនៅដ្ឋានខាង និង នៅសាលាឃុំ ឬ សាលាសង្កាត់នៃសាមីខ្លួននារី ០១ច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួនបុរស ០១ ច្បាប់។ ប័ណ្ណប្រកាសត្រូវចុះ ៖

• នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្តី ប្រពន្ធ។

• នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ឪពុកម្តាយនៃអនាគត ប្តីប្រពន្ធ បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់។[35]

**២.១.២.៣. រយៈពេលប្តឹងជំទាស់**

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបានប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍នោះ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍ លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់។[36]

**២.១.២.៤. ការចុះសំបុត្រអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍គឺជា កិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងនារីម្នាក់ដែលប្តេជ្ញាថានឹងខ្លួននឹងរួមសមគ្គសង្វាសនឹងគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ក៏តម្រូវឲ្យភាគីទាំងសងខាងគោរពទៅលើលក្ខខណ្ឌទម្រង់ផងដែរ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយដែលរួចផុតពីមោឃភាព។ បន្ទាប់ពីការដាក់ពាក្យស្នើសុំការរៀបអាពាហ៍ពិពាហ៍ ការប្រកាសផ្សាយជាសាធារណៈ និងផុតរយៈពេលប្តឹងជំទាស់ ឬ ការដោះស្រាយការប្តឹងជំទាស់រួចរាល់ដោយសមត្ថកិច្ច បុរស និង នារី ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នាអាចចុះសំបុត្រអាពាហ៍ពិពាហ៍បាន។

[34] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន , មាត្រា ២៨

[35] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន , មាត្រា ២៩

[36] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន , មាត្រា ២៩

អាពាហ៍ពិពាហ៍អាចចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តយកទទួលគ្នាជា ប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការ ចំនួន ០២នាក់ផង។[37]

ពេលសាមីខ្លួនជាអនាគត ប្តី និងប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយប្រគល់អោយសាមីខ្លួន ប្តីប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។[38]

## ២.២ អនុភាពនៃអាពាហ៍ពិពាហ៍

តាមច្បាប់ បន្ទាប់ពីភាគីទាំងសងខាងបានរៀបអាពាហ៍ពិពាហ៍រួច គូភាគីនៃអាពាហ៍ពិពាហ៍នឹងក្លាយជាសហព័ទ្ធ។ ដូច្នេះ ក្នុងឋានៈជាសហព័ទ្ធនេះបានផ្តល់សិទ្ធិ និងករណីយកិច្ចមួយចំនួន ទាំងក្នុងទិដ្ឋភាពទាក់ទងនឹងទ្រព្យសម្បត្តិ ព្រមទាំងទិដ្ឋភាពនៃករណីយកិច្ចរបស់សហព័ទ្ធ។

### ២.២.១ សិទ្ធិរបស់សហព័ទ្ធ

បន្ទាប់ពីអាពាហ៍ពិពាហ៍រួច សហព័ទ្ធមានសិទ្ធិផ្សេងៗ ដែលមានចែងនៅក្នុងច្បាប់ជាធរមាន ដែលសិទ្ធិទាំងនោះមានដូចជា សិទ្ធិប្រើប្រាស់នាមត្រកូល សិទ្ធិបង្កើតប្រព័ន្ធទ្រព្យសម្បត្តិជាដើម ដើម្បីកំណត់ផលប្រយោជន៍រៀងៗខ្លួននៅក្នុងគ្រួសារ។

#### ២.២.១.១ ការប្រើប្រាស់នាមត្រកូល

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ដែលធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបទបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងនៅក្នុងច្បាប់។

ផ្អែកតាមក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា អាពាហ៍ពិពាហ៍ដែលស្របទៅតាមគតិយុត្តិក៏បើកលទ្ធភាពដល់សហព័ទ្ធម្ខាងក្នុងការប្រើប្រាស់នាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬប្រើនាមត្រកូលរៀងខ្លួនៗ ដែលមានមុនអាពាហ៍ពិពាហ៍បាន។[39] មានន័យថា នាមត្រកូលរបស់ប្តី និងប្រពន្ធអាចដូចគ្នា និងអាចខុសគ្នា។

[37] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន , មាត្រា ៣០

[38] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន , មាត្រា ៣១

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៥

ឧទាហរណ៍ ៖ លោក សុខ សម្បត្តិ បានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ជាមួយអ្នកស្រី គង់ បញ្ញា។ ក្នុងករណីនេះ អ្នកស្រី គង់ បញ្ញា អាចប្រើនាមត្រកូលរបស់ប្តីនាងបាន ដោយប្តូរទៅជា លោកស្រី សុខ បញ្ញា វិញក៏បានដែរ។

**២.២.១.២ ការទទួលបាននីតិភាព**

ក្រមរដ្ឋប្បវេណីបានចែងថា ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះបានចាត់ថាដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ។ ក្រមរដ្ឋប្បវេណីក៏បានបញ្ជាក់ដែរថា អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ នឹងត្រូវទទួលអគ្គាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការ។[40] អនីតិជនដែលទទួលអគ្គាធីនភាពត្រូវចាត់ទុកថាបានដល់នីតិភាព។

ទាំងអស់នេះមានន័យថា អាពាហ៍ពិពាហ៍នាំមកនូវអគ្គាធីនភាពដល់អនីតិជនដោយស្វ័យប្រវត្តិ ដោយនីតិភាពនេះនឹងមិនបាត់បង់ឡើយទោះបីជាការលែងលះកើតមានឡើងក៏ដោយ។ អនិតិជនដែលចាត់ទុកជានីតិជន អាចមិនត្រឹមតែបានទទួលសមត្ថភាពនៅក្នុងការធ្វើសកម្មភាពស្របច្បាប់ទាក់ទងនឹងទ្រព្យសម្បត្តិនោះទេ តែថែមទាំងអាចធ្វើសកម្មភាពឋានៈបុគ្គលក៏ដូចជាសកម្មភាពនៅក្នុងអាជីវកម្ម អាពាហ៍ពិពាហ៍ផ្សេងទៀតដោយឯករាជ្យ ដោយមិនចាំបាច់មានការអន្តរាគមន៍ពីឪពុកម្តាយ។

**២.២.១.៣ សេរីភាពជ្រើសរើសវិជ្ជាជីវៈ**

បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍តាមច្បាប់ រួចរាល់ សហព័ទ្ធនៃអាពាហ៍ពិពាហ៍ត្រូវបានអនុញ្ញាតឲ្យមានសិទ្ធិសេរីភាពរៀងៗខ្លួននៅក្នុងការជ្រើសរើសវិជ្ជាជីវៈ។ នៅក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាប្តីប្រពន្ធមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈនិងសិទ្ធិចូលរួមប្រាស្រ័យដោយសេរីភាពក្នុងសកម្មភាពនយោបាយ វប្បធម៌និងសង្គម។ ប្តីប្រពន្ធ ត្រូវបន្តគោរពនូវសិទ្ធិបុគ្គលចំពោះសេរីភាពនៅក្នុងការជ្រើសរើសការចូលរួម ក្នុងវិជ្ជាជីវៈក្នុងនាមជាដៃគូជាមួយភាគីម្ខាងទៀត និងសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌និងសង្គមដោយរដ្ឋធម្មនុញ្ញបានចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មកក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌របស់ប្រទេសជាតិ។[41]

**២.២.១.៤ ការអាស្រ័យនៅទ្រព្យដោយឡែករបស់សហព័ទ្ធ**

ដើម្បឲ្យមានភាពងាយស្រួលនៅក្នុងការបែងចែកនូវទ្រព្យសម្បត្តិសហព័ទ្ធនៅពេលលែងលះ ក្រមរដ្ឋប្បវេណីខ្មែរ ទ្រព្យសម្បត្តិសហព័ទ្ធដែលកំណត់ទៅតាមច្បាប់កំណត់ បែងចែកជាពីរ គឺទ្រព្យសម្បត្តិរួម និងដោយឡែក។ ទ្រព្យដោយឡែក គឺជាទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែលទទួល

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៧

បានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និងទ្រព្យដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀតនឹងរាប់ជាទ្រព្យដោយឡែក។

សហព័ទ្ធម្ខាងៗនៃអាពាហ៍ពិពាហ៍មានសិទ្ធិអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាង ក្នុងករណីដែលទ្រព្យសម្បត្តិនោះត្រូវបានប្រើប្រាស់ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់ប្តីប្រពន្ធ។ ទោះបីជាសហព័ទ្ធសម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏សហព័ទ្ធអាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ។[42]

**២.២.១.៥ ការបង្កើតរបបសុំកូនពេញលេញ**

របបសុំកូនគឺជារបបមួយដែលបានបង្កើតទំនាក់ទំនងញតិភាពរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹមដែលស្របទៅតាមច្បាប់ក្នុងគោលដៅធ្វើឲ្យកូនសុំអាចបានរស់នៅក្នុងមជ្ឈដ្ឋានថ្មីដោយគេចផុតពីភាពក្រីក្រ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬការរំលោភបំពានផ្សេងៗទៅលើកុមារ។បុគ្គលដែលមានសហព័ទ្ធ អាចបង្កើតរបបសុំកូនពេញលេញបាន។ យោងតាមមាត្រា ១០០៨ នៃក្រមរដ្ឋប្បវេណីបានចែងថា បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ ពាក្យសហព័ទ្ធដែលមានចែងនៅក្នុងមាត្រា១០០៨ សំដៅទៅលើសហព័ទ្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬសហព័ទ្ធ ក្នុងន័យជាអនីតិសង្វាស? វាជាការលំបាកក្នុងការបកស្រាយ ប៉ុន្តែតាមទស្សនាទាននៃផ្នត់គំនិតរបស់ក្រមរដ្ឋប្បវេណីសំដៅទៅលើការប្រើប្រាស់ចំពោះអ្នកដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ។

ក្រៅពីនេះ ការតម្រូវឲ្យមានសហព័ទ្ធក្នុងការសុំកូនពេញលេញជាលក្ខខណ្ឌមួយដើម្បីធានាការពារផលប្រយោជន៍ដល់កូនដែលត្រូវយកទៅចិញ្ចឹមផងដែរ។

**២.២.១.៦ ការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**

ផ្អែកតាមស្មារតីក្រមរដ្ឋប្បវេណី គេឃើញមានប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធចំនួនពីរ គឺប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។ គូភាគីនៃអាពាហ៍ពិពាហ៍មានសិទ្ធិយ៉ាងពេញលេញនៅក្នុងការជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិដើម្បីផលប្រយោជន៍សម្រាប់គ្រួសាររបស់ខ្លួន អំណះអំណាងនេះត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី។

**ក.ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា**

ជាគោលការណ៍ ដើម្បីអាចជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា សហព័ទ្ធត្រូវធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ មួយវិញទៀត កិច្ចសន្យាត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅមុន ឬនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ។ ជាពិសេសទៅទៀត កិច្ចសន្យានេះត្រូវតែចុះបញ្ជីដើម្បីអាចយកមកតតាំងនឹងតតិយជន

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៧

បាន។ ម្យ៉ាងទៀត ការចុះបញ្ជីនេះត្រូវធ្វើនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ តាមពាក្យសុំចុះបញ្ជីរបស់ប្តីប្រពន្ធ ឬបុគ្គលដែលនឹងរៀបការជាមួយគ្នាដោយផ្អែកតាមបទប្បញ្ញត្តិនៃមាត្រា ២៦ និងមាត្រា ២៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

យ៉ាងណាមិញ ពាក្យថា លក្ខខណ្ឌតតាំង គឺចង់សំដៅទៅលើលក្ខខណ្ឌដែលត្រូវបំពេញ ដើម្បីឲ្យមានអនុភាពទៅលើតតិយជន ក្រៅពីគូភាគី។ ដូច្នេះ កង្វះលក្ខខណ្ឌតតាំង នឹងនាំឲ្យតតិយជនអាចជំទាស់ចំពោះអនុភាពនៃកិច្ចសន្យាចំពោះរូបគាត់បាន។

**ខ.ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់**

នៅក្នុងករណីដែលសហព័ទ្ធមិនបានធ្វើកិច្ចសន្យាស្តីពីទ្រព្យសម្បត្តិនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬអំឡុងពេលអាពាហ៍ពិពាហ៍ទេនោះ ច្បាប់បានសន្មត ឬសច្ចាធារណ៍ថាសហព័ទ្ធនឹងប្រកាន់យកនូវប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមការកំណត់របស់ច្បាប់។ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ នឹងមិនទាមទារឲ្យមានការចុះបញ្ជីទេ ដែលខុសពីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាដែលការចុះបញ្ជីគឺជាការចាំបាច់ដើម្បីឲ្យកើតមានអនុភាពគតិយុត្តិ។

**ខ.១ ទ្រព្យសម្បត្តិដោយឡែក**

ផ្អែកតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា ទ្រព្យដោយឡែកគឺជាទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមកម្មសិទ្ធរបស់សហព័ទ្ធណាម្នាក់ ដែលទ្រព្យទាំងនោះមានដូចជា ៖

• ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍

ឧទាហរណ៍ ៖ លោក រតនា បានធ្វើការសន្សំលុយទិញដីមួយកន្លែងនៅជាយក្រុងភ្នំពេញ។ ពីរឆ្នាំក្រោយមកគាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា ពិសី ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍។ ដូចនេះ ដីមួយកន្លែងខាងលើជាទ្រព្យសម្បត្តិដោយឡែករបស់លោក រតនា។ ដូចនេះ លោក រតនាអាចចាត់ចែងទ្រព្យសម្បត្តិដោយឡែកបានដោយសេរី។

• ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម ឬសន្តតិកម្ម ឬ អច្ច័យទាន នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍

ឧទាហរណ៍ ៖ ដូចគ្នាទៅនឹងករណីខាងលើ នៅថ្ងៃរៀបអាពាហ៍ពិពាហ៍ចូលមកដល់រវាងលោក រតនា និងកញ្ញា ពិសី ស្រាប់ឪពុកម្តាយបង្កើតរបស់កញ្ញា ពិសី បានប្រទានកម្មនូវចិញ្ចៀនពេជ្រ ១វង់។ ដូច្នេះ ចិញ្ចៀនពេជ្រ១វង់ ខាងលើគឺជាទ្រព្យដោយឡែករបស់កញ្ញា ពិសី។ ដូចនេះ កញ្ញា ពិសី អាចធ្វើការចាត់ចែងទ្រព្យដោយឡែករបស់នាងបានដោយសេរី។

សូមធ្វើការកត់សម្គាល់ថា ប្រសិនបើទាយកធ្វើប្រទានកម្មឲ្យសហព័ទ្ធទាំងសងខាង គួរចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។ យ៉ាងណាមិញ ប្រសិនបើទាយកមិនបានបង្ហាញឆន្ទៈច្បាស់លាស់វិញ គេត្រូវពិនិត្យមើលទៅលើស្ថានភាពជាក់ស្តែងនៃទ្រព្យនោះ។

ឧទាហរណ៍ ៖ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍រវាងលោក សំខាន់ និងលោកស្រី ណារី ម្តាយមីងរបស់លោក សំខាន់ បានចងដៃនូវរថយន្តមួយគ្រឿង។ ក្នុងស្ថានភាពបែបនេះ គួរចាត់ទុកថា រថយន្តនោះគឺជាទ្រព្យសម្បត្តិរួម ពីព្រោះថាការចងដៃ គឺសម្រាប់ទាំងពីរនាក់ មិនមែនសម្រាប់តែកូនក្រមុំ ឬ កូនកម្លោះនោះទេ។

• ទ្រព្យសម្បត្តិដែលជាតម្លៃតប ទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក

ឧទាហរណ៍ ៖ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី បញ្ញា លោក សម្បត្តិមានទ្រព្យដូចជាដីមួយកន្លែង និងរថយន្តមួយគ្រឿងដែលគេចាត់ទុកជាទ្រព្យដោយឡែករបស់លោក បញ្ញា។ នៅពេលដីធ្លីកំពុងឡើងថ្លៃ ស្រាប់តែលោក បញ្ញា បានសម្រេចចិត្តលក់ដីមួយកន្លែងនោះ។ នៅក្នុងករណីបែបនេះ ប្រាក់ដែលបានពីការលក់ដីត្រូវចាត់ទុកថាជាទ្រព្យដោយឡែក។

**ខ.២ ទ្រព្យសម្បត្តិរួម**

នៅក្នុងច្បាប់ ទ្រព្យសម្បត្តិកំណត់ដោយច្បាប់បែងចែកជាពីរគឺ ទ្រព្យរួម និងទ្រព្យដោយឡែក ដើម្បីកំណត់ស្ថានភាពទ្រព្យសម្បត្តិនៅមុនពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិមាននៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដែលងាយស្រួលបែងចែកនៅពេលលែងលះ។

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[43] ដូច្នេះ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធមានដូចជា ចំណូលដែលបានមកពីការងាររបស់សហព័ទ្ធដូចជាប្រាក់បៀវត្ស។ល។ ក៏ដូចជាផលនៃទ្រព្យដោយឡែកជាដើម។

ឧទាហរណ៍ ៖ លោក សំណាង បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកស្រី ហត្ថា តាំងពីឆ្នាំ ២០១៥។ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លោក សំណាង និង អ្នកស្រីហត្ថា បានសម្រេចចិត្តជាមួយគ្នាក្នុងការបើកអាជីវកម្មលក់ដូរមួយកន្លែងក្បែរផ្សារដើមគរ។ នៅក្នុងអាជីវកម្មនោះ លោក សំណាង និងអ្នកស្រី ហត្ថា បានប្រាក់ចំណូលចំនួន ១០០០ ដុល្លារក្នុងមួយខែ។ ដូច្នេះ ប្រាក់ចំណូល ១០០០ ដុល្លារនៅក្នុងមួយខែនោះ គឺជាទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរ។

ឧទាហរណ៍ ៖ លោក ដេវីត និងអ្នកស្រី សុខា គឺជាសហព័ទ្ធនឹងគ្នាស្របទៅតាមច្បាប់។ នៅមុនពេលរៀបអាពាហ៍ពិពាហ៍លោក ដេវីត មានផ្ទះមួយកន្លែងដែលច្បាប់បានចាត់ទុកថាជាទ្រព្យដោយឡែក។ ដោយសារស្ថានភាពនៅក្នុងគ្រួសារមិនសូវមានភាពធូរធារ លោក ដេវីត ក៏បានសម្រេចចិត្តយកផ្ទះរបស់ខ្លួនដែលជាទ្រព្យ

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣

ដោយឡែកទៅធ្វើកតិសន្យាជាមួយភាគីម្ខាងទៀតដែលទទួលកម្រៃចំនួន៥០០ ដុល្លារក្នុងមួយខែ។ ដូចនេះ ប្រាក់ចំនួន ៥០០ដុល្លារ ដែលជាផលនៃទ្រព្យដោយឡែកត្រូវចាត់ទុកថាជាទ្រព្យរួម។

ដោយឡែក ចំពោះកម្មសិទ្ធិបញ្ញា ដូចជាសិទ្ធិអ្នកនិពន្ធជាដើម គឺត្រូវធ្វើការបែងចែករវាងសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ។ ដូច្នេះ ប្រាក់កម្រៃដែលបានមកពីការធ្វើអាជីវកម្មលើស្នាដៃដែលទទួលបាន ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ គឺត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។

ឧទាហរណ៍ ៖ លោក សេរី បាននិពន្ធសៀវភៅមួយក្បាលដែលមានចំណងជើងថា ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា នៅឆ្នាំ ២០១៥ ។ នៅឆ្នាំ ២០២០ លោក សេរី បានរៀបអាពាហ៍ពិពាហ៍បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកស្រី ធីតា។ នៅឆ្នាំ ២០២១ នេះ គាត់បានលក់សៀវភៅដែលជាស្នាដៃរបស់គាត់បានចំនួន ២០០ ក្បាល គឺបានកម្រៃចំនួន ១០០០ ដុល្លារ។ ដូចនេះ ប្រាក់ចំនួន ១០០០ ដុល្លារគឺជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។

**ខ.២.១ ការគ្រប់គ្រងទ្រព្យសម្បត្តិរួម**

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលគូសហព័ទ្ធរកបាននៅអំឡុងពេលអាពាហ៍ពិពាហ៍។

សម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរួមវិញ សហព័ទ្ធទាំងសងខាងមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម ក្នុងទំហំចាំបាច់ដោយផ្អែកទៅលើជីវភាពគ្រួសារ។ តាមពិតសហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។ សូមកត់សម្គាល់ថាពាក្យ គ្រប់គ្រង គឺជាពាក្យដែលមានន័យមិនសូវច្បាស់លាស់ ហើយក្រមរដ្ឋប្បវេណីក៏មិនបានផ្ដល់និយមន័យជាក់លាក់ចំពោះពាក្យនេះផងដែរ។ ដូច្នេះការជួសជុលទ្រព្យសម្បត្តិរួម ការជួលទ្រព្យសម្បត្តិរួម ក៏គួរតែត្រូវចាត់ទុកថាជាសកម្មភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរួមដូច្នោះដែរ។

**ខ.២.២ ការចាត់ចែងទ្រព្យសម្បត្តិរួម**

លើសពីនេះទៅទៀត ចំពោះការចាត់ចែងទ្រព្យសម្បត្តិរួម បើផ្អែកតាមក្រមរដ្ឋប្បវេណីមាត្រា ៩៧៦ គឺតម្រូវឲ្យមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង។ ក៏ប៉ុន្តែ បើមានស្ថានភាពមិនអាចជៀសវាងបាន ដើម្បីថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីថែរក្សាជីវភាពរស់នៅ ប្ដី ឬប្រពន្ធអាចលក់ ឬធ្វើការចាត់ចែងដោយទទួលបានការអនុញ្ញាតពីតុលាការ។

យ៉ាងណាមិញ នៅក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាងបានធ្វើការចាត់ចែងទ្រព្យសម្បត្តិរួម ដោយពុំមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬក៏ពុំមានការអនុញ្ញាតពីតុលាការទេ ភាគីម្ខាងទៀតអាចទាមទារឲ្យតុលាការសម្រេចលុបចោលការចាត់ចែងនោះបាន។ បើជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រមអាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាននៅក្នុងអំឡុងពេល ២ឆ្នាំ គិតចាប់ពីពេលដែលដឹងអំពីការចាត់ចែងនោះ បើសិនជាទ្រព្យផ្សេងទៀត សហព័ទ្ធដែល

មិនបានផ្តល់ការយល់ព្រមអាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាននៅក្នុងអំឡុងពេល ១ឆ្នាំ គិតចាប់ពីពេលដឹងអំពីការចាត់ចែងនោះ។

**២.២.២ ករណីយកិច្ចរបស់សហព័ទ្ធ**

នៅពេលដែលអាពាហ៍ពិពាហ៍បង្កើតអនុភាព សហព័ទ្ធនីមួយៗ ក៏មានករណីយកិច្ចដូចគ្នាទៅនឹងសិទ្ធិផងដែរ ។ ករណីយកិច្ចទាំងនោះមានដូចជា ករណីយកិច្ចរួមរស់ជាមួយគ្នា និង ករណីយកិច្ចទទួលខុសត្រូវរួម។

**២.២.២.១ ករណីយកិច្ចរួមរស់ជាមួយគ្នា**

អាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធផ្លូវចិត្ត រាងកាយ និងសេដ្ឋកិច្ចនៃប្តីប្រពន្ធ ដូច្នេះ ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នាហើយសហការសង្គ្រោះគ្នាទៅវិញទៅមកដោយប្តីប្រពន្ធត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនះ។ ប្តីប្រពន្ធមានករណីយកិច្ចស្រលាញ់គ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពព្រមទាំងកសាងគ្រួសារមួយដែលមានសាមគ្គីភាពនិងប្រកបដោយសុភមង្គល។ មួយវិញទៀត ប្តីប្រពន្ធគឺជាបុគ្គលឯករាជ្យនិងស្មើភាពគ្នា ត្រូវមានករណីយកិច្ចសហការគ្នាដើម្បីថែរក្សាជីវភាពអាពាហ៍ពិពាហ៍រួមហើយទន្ទឹមនឹងនេះដើម្បីឆ្លើយតបទៅនឹងករណីយកិច្ចនេះ គឺពួកគេមានសិទ្ធិស្មើៗគ្នា។[44]

**២.២.២.២ ករណីយកិច្ចបង្ការអំពើហិង្សានៅក្នុងគ្រួសារ**

នៅប្រទេសកម្ពុជា អំពើហិង្សានៅក្នុងគ្រួសារមានសភាពធ្ងន់ធ្ងរហើយមានករណីខ្លះដែលការជួញដូរនិងរំលោភបំពានលើកុមារត្រូវបានយល់ច្រឡំថាជាសិទ្ធិអំណាចរបស់ឪពុកម្តាយថែមទៀតផង។ ហេតុដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបានតម្រូវឲ្យសមាជិកម្នាក់ៗនៅក្នុងគ្រួសារមានករណីយកិច្ចគោរពសិទ្ធិ និងសេរីភាពរវាងគ្នាទៅវិញទៅមកនិងជួយសង្គ្រោះគ្នាទៅវិញទៅមកដើម្បីភាពសុខដុមនៅក្នុងគ្រួសារ នេះបានសបញ្ជាក់ឲ្យឃើញថាសិទ្ធិរបស់សមាជិកម្នាក់ៗនៅក្នុងគ្រួសារត្រូវបានការពារដោយផ្លូវច្បាប់ ហើយព្រមជាមួយគ្នានេះដែរ បន្ថែមពីនេះទៅទៀតក្រមរដ្ឋប្បវេណីក៏បានបញ្ជាក់ពីស្មារតីនៃកាតព្វកិច្ចជួយគ្នាទៅវិញទៅមកក្នុងគ្រួសារដែលជាសហគមន៍ដែលមានជីវភាពរួមគ្នា។ ច្បាប់បានដាក់បន្ទុកលើសមាជិកគ្រួសារម្នាក់ៗនូវករណីយកិច្ចដើម្បីក្នុងការធានាសុវត្ថិភាពនិងសន្តិភាពនៅក្នុងគ្រួសារ ដែលកំណត់ឲ្យមាននៅករណីយកិច្ចក្នុងការទប់ស្កាត់អំពើហិង្សានិងការរំលោភបំពានសិទ្ធិកុមារនៅក្នុងគ្រួសារ។[45]

**២.២.២.៣ ករណីយកិច្ចទទួលខុសត្រូវរួមរបស់សហព័ទ្ធ**

ប្តីនិងប្រពន្ធ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ហើយ ប្តីនិងប្រពន្ធមានករណីយកិច្ចត្រូវទទួលខុសត្រូវរួមដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលច្បាប់កំណត់ដូចជា ៖

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៦
[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៣

• សោហ៊ុយដើម្បីថែរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាលកូន ជាអាទិ៍។

• កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងទៀត ដែលប្ដី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។

• សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម

នៅក្នុងករណីដែលសហព័ទ្ធម្ខាងបានជាប់បំណុលអ្នកដទៃដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀត ដែលបំណុលនោះសហព័ទ្ធម្ខាងបានយកទៅប្រើប្រាស់មិនបម្រើឲ្យផលប្រយោជន៍នៅក្នុងគ្រួសារ ពោលគឺការបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន សហព័ទ្ធនោះត្រូវតែទទួលខុសត្រូវចំពោះកាតព្វកិច្ចតែម្នាក់ឯង ។ ប៉ុន្តែនៅលក្ខខណ្ឌដែលបំណុលនោះ សហព័ទ្ធបានយកមកប្រើប្រាស់ក្នុងន័យដើម្បីថែរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ ឬ ការព្យាបាលនិងអប់រំកូន ទោះបីជាសហព័ទ្ធម្ខាងទៀតមិនបានយល់ព្រមជាលាយលក្ខណ៍អក្សរក៏ដោយ ក៏សហព័ទ្ធម្ខាងទៀតត្រូវមានករណីយកិច្ចទទួលខុសត្រូវដោយសាមគ្គីភាពផងដែរ។

ឧទាហរណ៍ ៖ អ្នកស្រី សុខលាភ បានខ្ចីបំណុលអ្នកជិតខាងចំនួន ២លានរៀល ក្នុងគោលបំណងព្យាបាលជម្ងឺកូនប្រុសខ្លួន។ ការខ្ចីបំណុលនេះបានធ្វើឡើងដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីលោក ពិសិដ្ឋ ដែលជាស្វាមីទេ។ ទោះបីជាបែបនេះក្ដី ក៏លោក ពិសិដ្ឋ ក៏ត្រូវទទួលខុសត្រូវរួមជាមួយអ្នកស្រី សុខលាភ ផងដែរ ពីព្រោះការខ្ចីបំណុលខាងលើក្នុងគោលបំណងព្យាបាលជម្ងឺឲ្យកូនប្រុស។

# ជំពូកទី៣ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋថៃនិងថៃ

## ៣.១. លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

ព្រះរាជាណាចក្រថៃគឺជាប្រទេសមួយដែលប្រជាជនភាគច្រើនគោរពទៅលើសាសនាព្រះពុទ្ធ និងមានប្រពៃណីទំនៀមទម្លាប់ដូចជាប្រទេសកម្ពុជាដែរ។ទំនៀមទំលាប់ប្រពៃណីនៃប្រទេសថៃគឺរាល់ពេលមានការប្រារព្ធនូវការរៀបអាពាហ៍ពិពាហ៍កើតឡើង គឺតែងតែលេចឡើងនូវទិដ្ឋភាពនៃការរៀបអាពាហ៍ពិពាហ៍ពីរប្រភេទផ្សេងគ្នា គឺការរៀបអាពាហ៍ពិពាហ៍ទៅតាមទម្រង់ប្រពៃណីព្រះពុទ្ធសាសនា និងការរៀបអាពាហ៍ពិពាហ៍ទៅតាមទម្រង់គតិយុត្តិតាម រយៈការចុះអត្រានុកូលដ្ឋាន។[46]

ផ្អែកទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយដែលមានភាពត្រឹមត្រូវទៅតាមច្បាប់ គឺតម្រូវឲ្យភាគីទាំងសងខាងគោរពឲ្យបានខ្ជាប់ខ្ជួនទៅនឹងលក្ខខណ្ឌចម្បងចំនួនពីរគឺលក្ខខណ្ឌច្បាប់ និងលក្ខខណ្ឌទម្រង់។ ការមិនគោរពទៅតាមលក្ខខណ្ឌដែលបានបញ្ញត្តិនៅក្នុងច្បាប់អាចជាបច្ច័យមួយក្នុងមូលហេតុផ្លូវច្បាប់ដែលអាចធ្វើឲ្យអាពាហ៍ពិពាហ៍របស់ពួកគេអាចប្រឈមទៅនឹងការលុបចោលឬអាចនឹងមោឃភាព។

### ៣.១.១. លក្ខខណ្ឌច្បាប់

អាពាហ៍ពិពាហ៍ គឺជាការយល់ព្រមរវាងបុរសនិងស្ត្រីក្នុងការយកគ្នាជាប្តីប្រពន្ធដើម្បីរួមរស់ជាមួយគ្នាក្នុងគោលដៅបង្កើតគ្រួសារមួយដែលមានសុភមង្គល។ដើម្បីអាចឲ្យអាពាហ៍ពិពាហ៍របស់ពួកគេអាចគេចផុតពីការលុបចោល ឬធ្វើឲ្យអាពាហ៍ពិពាហ៍របស់ពួកគេមានសុពលភាព គឺភាគីទាំងសងខាងត្រូវគោរពលក្ខខណ្ឌនានាដែលមានចែងនៅក្នុងច្បាប់ជាធរមាន។

#### ៣.១.១.១. លក្ខខណ្ឌអាយុ

លក្ខខណ្ឌអាយុ គឺជាលក្ខខណ្ឌដែលកំណត់ពីវ័យនីតិភាពនៅក្នុងការបង្ហាញឆន្ទៈក្នុងការយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍។

ដូចបាននិយាយខាងលើ អាពាហ៍ពិពាហ៍គឺជាការយល់ព្រមរវាងបុរសនិងស្ត្រីក្នុងការយល់ព្រមក្នុងការយកគ្នាជាប្តីប្រពន្ធ។ ផ្អែកតាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រថៃបានកំណត់អាយុនៅក្នុងការយល់ព្រមក្នុងការបង្ហាញឆន្ទៈនៅក្នុងការជ្រើសរើសគូស្រករដើម្បីបំពេញអត្ថន័យជីវិត។ ក្រមរដ្ឋប្បវេណីនៃប្រទេសថៃបានបញ្ញត្តិថាបុរសនិងនារីដែលមិនទាន់ពេញវ័យគឺមិនអាចបង្ហាញឆន្ទៈបានទេនៅក្នុងការរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍អាចនឹងប្រព្រឹត្តិទៅតាមផ្លូវច្បាប់បាន លុះត្រាតែបុរសនិងនារីមានអាយុមិនតិចជាង ១៧ឆ្នាំ។[47]

[46] www.esapeartist.com/blog/traditional-thai-wedding-ceremony-need-know
[47] Thai Civil and Commercial Code , Section 1448

ឧទាហរណ៍ ៖ លោក ស៊ុមសាក់ និងនារី អនង្គ មានអាយុ១៦ឆ្នាំ ដែលជាមិត្តភក្តិនឹងគ្នាដែលរៀននៅថ្នាក់កម្រិតវិទ្យាល័យជាមួយគ្នា។ លុះពេលក្រោយមក ពួកគេទាំងពីរបានធ្វើសង្សារនឹងគ្នាហើយមានបំណងចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយហេតុថាបានស្គាល់ចិត្តស្គាល់ថ្លើមគ្នាច្បាស់។ ពួកគេទាំងពីរនាក់បានទៅសាកសួរពត៌មានពីមន្ត្រីអត្រានុកូលដ្ឋានស្តីពីនីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍។ ដោយមើលទៅលើឯកសារសម្គាល់ខ្លួននានា មន្ត្រីអត្រានុកូលដ្ឋានបានពន្យល់ប្រាប់ថា ពួកគេមានអាយុតិចជាង១៧ឆ្នាំគឺមិនអាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានទេ។

ទោះបីជាក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ បានបញ្ញត្តិនូវលក្ខខណ្ឌអាយុនៅក្នុងការបង្ហាញឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍យ៉ាងតឹងរឹងបែបនេះក្តី ក៏ក្រមរដ្ឋប្បវេណីនៃប្រទេសនេះបានបញ្ញត្តិនូវករណីលើកលែងផងដែរ ពោលគឺបើកលទ្ធភាពតាមផ្លូវច្បាប់ឲ្យបុរសនិងស្ត្រីអាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបាន ប្រសិនបើពួកគេមានហេតុផលសមស្រប ពោលគឺអាចទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យ។[48]

ឧទាហរណ៍ ៖ ដូចករណីផ្លូវច្បាប់ខាងលើ លោក ស៊ុមសាក់ និងនារីអនង្គ ពួកគេទាំងពីរនាក់មានអាជីវកម្មរៀងៗខ្លួនដែលអាចទ្រទ្រង់ជីវភាពរបស់ពួកគេបានដោយឯករាជ្យ។ លោក ស៊ុមសាក់ មានអាជីវកម្មមួយលក់សំលៀកបំពាក់តាមប្រព័ន្ធអនឡាញនិងនៅតាមផ្សារទំនើប រីឯ នារីអនង្គវិញ នាងមានអាជីវកម្មលក់គ្រឿងសម្អាងតាមផ្ទះនៅតាមប្រព័ន្ធអនឡាញ។ ដោយហេតុតែពួកគេទាំងពីរនាក់មានអាជីវកម្មរៀងៗខ្លួនដែលអាចចំណូលក្នុងការទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យ ពួកគេអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីរៀបអាពាហ៍ពិពាហ៍នឹងគ្នាបាន។ នៅក្នុងករណីដែលមានហេតុផលសមស្របបែបនេះ តុលាការអាចឲ្យអនុញ្ញាតឲ្យពួកគេរៀបអាពាហ៍ពិពាហ៍នឹងគ្នាបាន។

#### ៣.១.១.២. លក្ខខណ្ឌឯកទ្វេពន្ធភាព

របបទ្វេពន្ធភាព គឺរបបមួយដែល បុរសមានប្រពន្ធពីរនាក់ ឬ នារីមានប្តីពីរនាក់ ដែលរបបមួយនេះបានធ្វើឲ្យប៉ះពាល់យ៉ាងដល់សីលធម៌សង្គម និងសណ្តាប់ធ្នាប់សាធារណៈ រួមទាំងសេចក្តីថ្លៃថ្នូររបស់ស្ត្រីភេទដែលត្រូវបានគេលើកតម្កើង។

ដោយហេតុតែរបបនេះធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ ទើបច្បាប់នាសម័យទំនើបមិនយកមកអនុវត្ត។

ផ្អែកលើប្រវត្តិសាស្ត្រនៃប្រទេសថៃនៅមុនឆ្នាំ ១៩៣៥ ក្នុងប្រទេសសៀម[49]បានអនុវត្តរបបទ្វេពន្ធភាពយ៉ាងទូលំទូលាយដោយមានសេរីភាពនៅក្នុងសង្គមថៃនាសម័យនោះ។កាលសម័យនោះ បុរសដែលមានទ្រព្យ

[48] Thai Civil and Commercial Code , Section 1448

[49] នៅមុនឆ្នាំ ១៩៣៥ ប្រទេសថៃនាសម័យនោះមានឈ្មោះជាផ្លូវការជាប្រទេសសៀម នៅឆ្នាំ ១៩៣៨ នៅពេលដែល លោក ភិបុល សង្គ្រាម ឡើងធ្វើជានាយករដ្ឋមន្ត្រី លោកក៏បានប្រកាសផ្លាស់ឈ្មោះប្រទេសសៀមប្តូរទៅជាប្រទេសថៃ។

សម្បត្តិអាចរកភរិយាបានយ៉ាងច្រើនដែលច្បាប់បានអនុញ្ញាតក្នុងការផ្តល់សិទ្ធិឲ្យពួកគេ។ នៅសម័យកាលនោះច្បាប់គ្រួសារចាស់ដែលបានបញ្ញត្តិនៅក្នុងសង្គមសៀម បានបែងចែកប្រពន្ធជាបីថ្នាក់គឺ ៖

- Mia Glang Muang เมียกลางเมือง គឺជាភរិយាដែលបុរសបានរៀបការជាមួយ ឬ ប្រពន្ធទី១
- Mia Glang Norg เมียกลางนอก គឺជាភរិយាបន្ទាប់ ឬភរិយាទី២
- Mia Glang Tasee เมียกลางทาสี គឺជាភរិយាទាសករដែលបានទិញពីឪពុកម្តាយរបស់ពួកគេ

ទោះបីជាសម័យមុន បុរសអាចរៀបអាពាហ៍ពិពាហ៍បានច្រើនយ៉ាងនេះក្តី ក៏សម័យនោះមិនតម្រូវឲ្យចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ កូនដែលបានកើតពីភរិយាទាំងអស់នោះត្រូវបានច្បាប់ទទួលស្គាល់ថាជាកូនស្របច្បាប់ទៀតផង។

លុះមកដល់ខែតុលា ឆ្នាំ ១៩៣៥ ព្រះមហាក្សត្រសៀម ព្រះបាទជូឡាឡុងកនបានសម្រេចព្រះទ័យក្នុងការធ្វើការកំណែទម្រង់ប្រព័ន្ធច្បាប់ឡើងវិញដោយបោះបង់ចោលរបបទ្វេពន្ធភាពដើម្បីការសេចក្តីថ្លៃថ្នូររបស់ស្ត្រីថៃនិងជាពិសេសប្រពៃណីដ៏ល្អផូរផង់នៃប្រទេសមួយនេះ ពោលគឺបុរសនិងស្ត្រីមិនអាចមានសហាព័ទ្ធលើសពីពីរនាក់បានទៀតទេ ។[50]

ទោះបីជាប្រទេសថៃធ្លាប់មានអនុស្សាវរីយ៍ក្នុងការអនុវត្តរបបទ្វេពន្ធភាពពីអតីតកាលក្តី ក៏សម័យបច្ចុប្បន្ននេះក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃមិនអនុញ្ញាតឲ្យមានរបបទ្វេពន្ធភាពឲ្យមានវត្តមាននៅប្រទេសថៃនាសម័យទំនើបនាពេលបច្ចុប្បន្នទេ។ ការដែលច្បាប់ប្រទេសនេះបានបញ្ញត្តិបែបនេះគឺធ្វើយ៉ាងណាដើម្បីថែក្សាសណ្តាប់ធ្នាប់ប្រពៃណី ទំនៀមទំលាប់និងសីលធម៌របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គម ជាពិសេសរបបឯកពន្ធភាពក៏បានធានាការពារភាពស្មោះត្រង់រវាងសហាព័ទ្ធនិងសហាព័ទ្ធកុំឲ្យមានភាពផិតក្បត់។

យោងទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ បានចែងថាបុរសនិងស្ត្រីដែលមានសហាព័ទ្ធរួចមិនអាចរៀបអាពាហ៍ពិពាហ៍បានទៀតទេ។[51] មិនត្រឹមតែប៉ុណ្ណោះបទទ្វេពន្ធភាពក៏ជាបទល្មើសផងដែរ ដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌថៃ។ ជនដែលប្រព្រឹត្តិបទល្មើសទ្វេពន្ធភាពនឹងត្រូវទទួលទោសទៅតាមច្បាប់។[52]

ឧទាហរណ៍ ៖ លោក ស៊ុមឆាយ បានរៀបការជាមួយអ្នកស្រី ផនធីប កាលពីឆ្នាំមុនជាមួយគ្នាដោយចុះអត្រានុកូលដ្ឋានពោលគឺចុះសំបុត្រអាពាហ៍ពិពាហ៍។ លោក ស៊ុមឆាយ បានបើកក្រុមហ៊ុនអចលនទ្រព្យមួយនៅទីក្រុងបាងកក។ មួយរយៈពេលក្រោយមកលោក ស៊ុមឆាយ បានលួចស្រលាញ់គ្នាជាមួយបុគ្គលិកស្រីម្នាក់ឈ្មោះកញ្ញា ដកម៉ៃ ដែលធ្វើការនៅក្នុងក្រុមហ៊ុនអចលនទ្រព្យដែលមានលោក ស៊ុមឆាយ ជាម្ចាស់ក្រុមហ៊ុន។ នៅពេលនោះលោក ស៊ុមឆាយ បានសន្យាជាមួយកញ្ញា ដកម៉ៃ ថាបើព្រមរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោក

[50] Thailawforum.com/articles/familywimol2.html
[51] Thai Civil and Commercial Code , Section 1452
[52] www.thailandlawonline.com/article-order-archieve/registeration-of-a-thai-marriage

លោកនឹងផ្តល់ផ្ទះ ឡាន និងតំណែងធំនៅក្នុងក្រុមហ៊ុនជារង្វាន់។ នៅក្នុងករណីបែបនេះ ទោះបីជាកញ្ញា ដកម៉ៃ បានយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយលោក ស៊ុមឆាយ ក៏ដោយក៏អ្នកទាំងពីរមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នាបានដែរ ពីព្រោះលោក ស៊ុមឆាយ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកស្រី ផនធីប រួចទៅហើយ ដោយចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាស្របទៅតាមច្បាប់ដែលបានកំណត់។

**៣.១.១.៣. លក្ខខណ្ឌទាក់ទងនឹងញាតិ**

ពិធីរៀបអាពាហ៍ពិពាហ៍មិនអាចកើតឡើងទេបើបុរសនិងស្ត្រីមានទំនាក់ទំនងឈាមជាមួយគ្នា ឬជាកូនចៅ ឬជាបងប្អូនជាមួយគ្នា។[53] ព្រោះថាការរៀបអាពាហ៍ពិពាហ៍បែបនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់សីលធម៌សង្គម សណ្តាប់ធ្នាប់សាធារណៈ និងប្រពៃណីដ៏ល្អផូរផង់របស់ប្រទេស។

ការរៀបអាពាហ៍ពិពាហ៍រវាងញាតិត្រូវបានហាមឃាត់ ដោយសារតែមូលហេតុនៃសុជាតិវិទ្យានិងមូលហេតុនៃសីលធម៌សង្គម។ ចំពោះមូលហេតុសុជាតិវិទ្យា ការរៀបអាពាហ៍ពិពាហ៍រវាងញាតិងាយបណ្តាលឲ្យពន្ធុខ្សោយជាប់គ្នា ហើយលទ្ធភាពនៃពិការភាពចំពោះកូនដែលមកកើនឡើងខ្ពស់។ ក៏ប៉ុន្តែការហាមឃាត់នូវអាពាហ៍ពិពាហ៍ចំពោះញាតិបែបនេះបណ្តាលមកពីមូលហេតុនៃសីលធម៌សង្គមច្រើនជាងហេតុផលសុជាតិវិទ្យា។ ជាឧទាហរណ៍នៅក្នុងសង្គម ការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈញាតិបែបនេះ និងបង្កឲ្យមានការរង្កៀសចិត្តគ្នាខាងផ្លូវភេទ ក្នុងចំណោមញាតិទាំងនោះហើយទិដ្ឋភាពនៃការចូលរួមនិងបរិយាកាសនៃការចិញ្ចឹមបីបាច់កូនក៏មិនមែនជាការគួរឲ្យប្រាថ្នាហើយក៏នឹងបណ្តាលឲ្យមានផលប៉ះពាល់ដល់ភាពសុខសាន្តនិងសុភមង្គលនៅក្នុងគ្រួសារដែលអាចឈានដល់ការបែកបាក់ផ្លូវចិត្តឬទំនាក់ទំនងញាតិតែម្តង ប្រសិនជាក្នុងពេលដែលកាលៈទេសៈណាមួយដែលចំណងអាពាហ៍ពិពាហ៍ត្រូវប្រេះឆា។

ឧទាហរណ៍ ៖ លោក អារុន និងកញ្ញា អាឆារ៉ា គឺជាពូហើយនិងក្មួយនឹងគ្នា។ ពួកគេមានទំនាក់ទំនងយ៉ាងស្និតរមួតជាមួយគ្នាដែលតែងតែទៅដំណើរកម្សាន្តជាមួយគ្នាជារឿយៗ។ ទំនាក់ទំនងបែបនេះយូរៗទៅ ពួកគេក៏មានចិត្តលួចស្រលាញ់គ្នាទៅវិញទៅមក រហូតដល់មានទំនាក់ទំនងស្នេហាជាមួយគ្នា។ ថ្ងៃមួយពួកគេចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នា ពួកគេបានទៅសាកសួរមេធាវីអំពីដំណើរការនីតិវិធីតាមផ្លូវច្បាប់នៃការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ មេធាវីរូបនោះក៏បានពន្យល់ប្រាប់ពួកគេវិញថា ពួកគេទាំងពីរនាក់មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ ពីព្រោះវាផ្ទុយនឹងច្បាប់ស្តីពីលក្ខខណ្ឌទាក់ទងនឹងញាតិដែលច្បាប់បានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ នឹងផលវិបាកនានាដែលកើតចេញពីការរៀបអាពាហ៍ពិពាហ៍ជាមួយជនដែលមានទំនាក់ទំនងញាតិជាមួយគ្នា។

[53] **Thai Civil and Commercial Code , Section 1450**

**៣.១.១.៤ លក្ខខណ្ឌទាក់ទងនឹងកូនសុំ**

ក្រមរដ្ឋប្បវេណីប្រទេសថៃ បានបញ្ញត្តិថាជនគ្រប់រូបដែលមានអាយុចាប់ពី២៥ឆ្នាំឡើងទៅអាចធ្វើការសុំកូនបាន។ ការសុំកូនអាចប្រព្រឹត្តិទៅបាននៅក្នុងលក្ខខណ្ឌដែលមានអ្នកសុំកូនមានអាយុច្រើនជាងកូនសុំចំនួន ១៥ឆ្នាំ។[54]

កម្មវត្ថុនៃការសុំកូន គឺផ្តោតសំខាន់ទៅលើគោលការណ៍មនុស្សធម៌សុទ្ធសាធ ដោយផ្សារភ្ជាប់ការយកចិត្តទុកដាក់ចំពោះកុមារ ដើម្បីការពារឲ្យរួចផុតពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោកបំពានផ្សេងៗជំនួសដោយការចិញ្ចឹមបីបាច់ថែរក្សា ការអប់រំរៀនសូត្រជាដើម។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាចក្រថៃបានហាមឃាត់ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹមឬម្ដាយចិញ្ចឹមជាមួយកូនសុំ ពីព្រោះការរៀបអាពាហ៍ពិពាហ៍ជាមួយកូនសុំអាចប៉ះពាល់ទៅដល់សីលធម៌សង្គម។

ឧទាហរណ៍ ៖ លោក អាវ៉ាន់ និងអ្នកស្រី កាំឡៃ បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាចំនួន ២៥ឆ្នាំមកហើយ។ អ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាច្រើនឆ្នាំប៉ុន្តែមិនមានបុត្រឡើយនៅក្នុងគ្រួសារ។ អ្នកទាំងបានគិតថាចង់សុំកូនស្រីម្នាក់ពីគ្រួសារក្រីក្រនៅតាមជនបទមកយកចិញ្ចឹម។ បន្ទាប់មកអ្នកទាំងពីរក៏បានសម្រេចចិត្តសុំកូនស្រីម្នាក់ពីគ្រួសារក្រីក្រម្នាក់ឈ្មោះកុមារី ចាន់តាណា អាយុ១៥ឆ្នាំ។ លុះដល់ពេលក្រោយមកអ្នកស្រី កាំឡៃ ក៏ទទួលមរណភាព ស្របពេលដែលកូនសុំ ចាន់តាណា បានចូលដល់ពេលពេញវ័យលោក អាវ៉ាន់ បែរជាពេញចិត្តស្រឡាញ់កូនសុំរបស់ខ្លួនទៅវិញ។ អ្នកទាំងពីរមានទំនាក់ទំនងស្នេហារួចចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ដោយមូលហេតុពួកគេគឺជា ឪពុកចិញ្ចឹមនិងកូនសុំ ពួកគេមិនអាចរៀបអាពាហ៍នឹងគ្នាបានទេ។

**៣.១.១.៥. លក្ខខណ្ឌទាក់ទងនឹងភេទ**

ប្រទេសថៃគឺជាប្រទេសភូមិផងរបងជាមួយកម្ពុជា ដែលមានប្រពៃណីទំនៀមទំលាប់ វប្បធម៌អរិយធម៌ស្រដៀងគ្នាទៅនឹងប្រទេសកម្ពុជាដែរ។ នៅក្នុងព្រះរាជាណាចក្រថៃ មានមនុស្សភេទទី៣ដ៏ច្រើនលើសលប់រស់នៅក្នុងសង្គមថៃបច្ចុប្បន្ន។ ពួកគេបានទទួលបានសិទ្ធិដូចប្រជាជនដទៃទៀតដែរ ជាពិសេសពួកគេបានទទួលបានការការពារពីការរើសអើងនានានៅក្នុងសង្គមផងដែរ។[55]

មិនខុសគ្នាទៅនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជានោះទេ គឺច្បាប់នៃព្រះរាជាណាចក្រថៃបានហាមឃាត់នូវការមិនឲ្យមានការរៀបអាពាហ៍ពិពាហ៍ឡើយរវាងភេទដូចគ្នា ( ខ្ទើយ) ។ ច្បាប់បានបញ្ញត្តិថា មានតែភេទដែលមានភាពខុសគ្នាតែប៉ុណ្ណោះទើបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍មួយដែលស្របទៅតាមច្បាប់ ។ ការអនុញ្ញាតឲ្យមានអាពាហ៍ពិពាហ៍មួយដែលមានភេទខុសគ្នា គឺមានផលប៉ះពាល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សង្គម។

[54] **Thai Civil and Commercial Code , Section 1451**
[55] **LGBT Rights in Thailand - Wikipedia**

ឧទាហរណ៍ ៖ លោក ស៊ីរ៉ែ និងលោក ថាណាវ៉ាត់ គឺជាមនុស្សភេទទី៣ និងជាមិត្តភក្តិសម្លាញ់នឹងគ្នា ដែលកំពុងរៀននៅថ្នាក់មហាវិទ្យាល័យជាមួយគ្នា។ ក្រោយពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រថ្មីៗ ពួកគេទាំងពីរនាក់បានផ្ដើមស្នេហានឹងគ្នា រួចមានបំណងចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នាថែមទៀតផង។ មួយឆ្នាំក្រោយមកពួកគេបានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយទៅសាលាស្រុកដើម្បីចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា។ ដោយសារអ្នកទាំងពីរមានភេទដូចគ្នាខុសទៅនឹងលក្ខខណ្ឌផ្លូវច្បាប់ មន្ត្រីអត្រានុកូលដ្ឋានក៏សម្រេចចិត្តមិនចុះសំបុត្រអាពាហ៍ពិពាហ៍ឲ្យទៅពួកគេ។

**៣.១.១.៦.លក្ខខណ្ឌវិធវភាព**

គោលការណ៍វិធវភាព គឺជាគោលការណ៍ដែលធ្វើឡើងតែចំពោះនារីប៉ុណ្ណោះ រីឯបុរសវិញមិនត្រូវបានច្បាប់ហាមឃាត់នោះទេនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដើម្បីកសាងគ្រួសារថ្មី នៅពេលដែលចំណងអាពាហ៍ពិពាហ៍បានរំលាយ។ ចំពោះបុរសវិញ គឺអាចរៀបអាពាហ៍ពិពាហ៍នៅពេលណាក៏បានឲ្យតែបានបញ្ចប់អាពាហ៍ពិពាហ៍ចាស់ពោលគឺបានលែងលះជាមួយសហព័ទ្ធមុន។ ចំពោះស្ត្រីវិញគឺរងចាំឲ្យផុតពីគោលការណ៍វិធវភាពនេះសិនដើម្បីឲ្យច្បាស់ថាតើកូននៅក្នុងផ្ទៃរបស់ស្ត្រីគឺជាកូនរបស់ប្ដីមុនឬរបស់ប្ដីក្រោយ។

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ បានបញ្ញត្តិថាស្ត្រីមិនអាចរៀបអាពាហ៍ពិពាហ៍បានទេ ប្រសិនបើក្នុងអំឡុងពេល ៣១០ថ្ងៃ ពុំបានកន្លងផុត។ ប៉ុន្តែ ក៏មានបញ្ញត្តិលើកលែងផងដែរនៅក្នុងករណី ៖

- ស្ត្រីមានផ្ទៃពោះ
- ស្ត្រីមិនមានផ្ទៃពោះ ដែលមានការបញ្ជាក់ពីវេជ្ជបណ្ឌិតជំនាញ
- មានការអនុញ្ញាតពីតុលាការ
- ការរៀបអាពាហ៍ពិពាហ៍ជាមួយអតីតសហព័ទ្ធដែលបានលែងលះ[56]

ឧទាហរណ៍ ៖ លោក ស៊ូរិត និងអ្នកស្រី ធិប្រាវ គឺជាប្ដីប្រពន្ធនឹងគ្នាអស់រយៈពេល៥ឆ្នាំ។ ការរស់នៅជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំ ពួកគេទាំងពីរនាក់រស់នៅមិនមានភាពចុះសម្រុងនឹងគ្នានោះទេគឺតែងតែមានភាពឈ្លោះទាស់ទែងជាមួយគ្នា។ ដោយសារតែមិនអាចរស់នៅជាប្ដីប្រពន្ធនឹងគ្នាបាន ពួកគេទាំងពីរនាក់ក៏បានសម្រេចចិត្តលែងលះគ្នានៅក្នុងតុលាការ។ ដោយហេតុតែមិនអាចរួមរស់ជីវភាពជាប្ដីប្រពន្ធនឹងគ្នាបានតទៅទៀត តុលាការក៏អនុញ្ញាតឲ្យពួកគេលែងលះគ្នា។ បន្ទាប់ពីលែងលះគ្នារួចជាមួយលោក ស៊ូរិត អស់រយៈពេលមួយខែ អ្នកស្រី ធិប្រាវ ក៏បានផ្ដើមស្នេហាថ្មីជាមួយលោក សារីត ដោយអ្នកស្រីចង់កសាងគ្រួសារថ្មីជាមួយនឹងលោក ។ បន្ទាប់ពីយល់ចិត្តគ្នារួច អ្នកស្រី ធិប្រាវ និងលោក សារីត ក៏បានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ អ្នកស្រី ធិប្រាវ និងលោក សារីត ក៏បានប្រកាសជាសាធារណនៅមុខមន្ត្រីអត្រានុកូលដ្ឋានថានឹងព្រមយក

[56] **Thai Civil and Commercial Code , Section 1453**

គ្នាជាប្តីប្រពន្ធក្នុងការកសាងគ្រួសារ ប៉ុន្តែអាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានមន្ត្រីអត្រានុកូលដ្ឋានបដិសេធពីព្រោះវាបានផ្ទុយទៅនឹងគោលការណ៍វិធវភាព។ ប្រសិនបើអ្នកស្រី ធិប្រាវ ចង់រៀបការជាមួយនឹងលោក សារីត អ្នកស្រីគួរតែបង្ហាញពីលិខិតបញ្ជាក់របស់វេជ្ជបណ្ឌិតបញ្ជាក់ថាគ្មានផ្ទៃពោះ ឬលិខិតអនុញ្ញាតពីតុលាការដែលអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍។

**៣.១.១.៧. លក្ខខណ្ឌមិនមានភាពវិបល្លាសស្មារតី**

នៅក្នុងការរៀបអាពាហ៍ពិពាហ៍ គឺតម្រូវឲ្យមានការបង្ហាញឆន្ទៈ ពេលគឺជនដែលមានបញ្ហាស្មារតីមិនអាចបង្ហាញឆន្ទៈបានទេ។

ជនដែលមានភាពវិបល្លាសស្មារតី ឬជនដែលមានភាពវិកលចរិកគឺច្បាប់នៃប្រទេសថៃមិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍បានទេ ពីព្រោះពួកគេគ្មានសមត្ថភាពអាចបង្ហាញឆន្ទៈព្រមព្រៀងយល់ព្រមនៅក្នុងការយកគ្នាជាប្តីប្រពន្ធ និងមិនអាចបង្ហាញឆន្ទះបានត្បិតការរៀបអាពាហ៍ពិពាហ៍គឺជាការយល់ព្រមយកគ្នាជាប្តីប្រពន្ធ ហើយការយល់ព្រមនេះត្រូវប្រកាសជាសាធារណៈនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[57]

ឧទាហរណ៍ ៖ លោក ឆៃសុន គឺជាជនដែលមានភាពវិបល្លាសស្មារតីដែលមិនអាចដឹងពីភាពខុសត្រូវនៃអំពើរបស់ខ្លួននោះទេ។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពបែបនេះក្តី លោក ឆៃសុន ចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារីឈ្មោះ ហាម។ នៅក្នុងករណីបែបនេះពួកគេទាំងពីរនាក់មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ ត្បិតភាគីម្ខាងមិនអាចបង្ហាញការយល់ព្រមនៅក្នុងការយកគ្នាជាប្តីប្រពន្ធ។ ដូច្នេះពួកគេទាំងពីរនាក់មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ។

**៣.១.២. លក្ខខណ្ឌទម្រង់**

ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយស្របទៅតាមច្បាប់កំណត់ គឺភាគីទាំងសងខាងមិនត្រឹមតែគោរពទៅតាមលក្ខខណ្ឌច្បាប់ប៉ុណ្ណោះទេ ថែមទាំងគោរពទៅតាមលក្ខខណ្ឌទម្រង់ថែមទៀតផង។

លក្ខខណ្ឌទម្រង់មានដូចជា ការប្រកាសជាសាធារណៈ និងការចុះសំបុត្រអាពាហ៍ពិពាហ៍។

**៣.១.២.១. ការប្រកាសជាសាធារណៈ**

អាពាហ៍ពិពាហ៍គឺជាមូលដ្ឋានមួយនៅក្នុងការបង្កើតគ្រួសារមួយដែលប្រកបដោយភាពកក់ក្តៅ ពីព្រោះបុរសនិងស្ត្រីបានស័គ្រចិត្តយកគ្នាជាស្វាមីភរិយាដែលមានគោលបំណងកសាងគ្រួសារមួយដែលជាកោសិកាសង្គម អនុវត្តភារៈសំខាន់របស់សង្គមគឺជាការបង្កើតភារៈពីការអប់រំ និងភារៈកសាងសេដ្ឋកិច្ច។

ម្យ៉ាងទៀតអាពាហ៍ពិពាហ៍ គឺជាចំណងមនោសញ្ចេតនារវាងបុរសម្នាក់និងនារីម្នាក់ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តនិងសមភាពហើយត្រូវបានច្បាប់ទទួលស្គាល់។

[57] **Thai Civil and Commercial Code , Section 1449**

ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយមានសុពលភាពទៅបាន គឺបុរសនិងស្ត្រីបានយល់ព្រមយកគ្នាជាប្តីប្រពន្ធ ហើយការព្រមព្រៀងគ្នានេះត្រូវបានប្រកាសជាសាធារណៈនៅមុខមន្ត្រីអត្រានុកូលដ្ឋាន។

ការយល់ព្រមប្រកាសជាសាធារណៈនៅមុខមន្ត្រីអត្រានុកូលដ្ឋាន ត្រូវបានធ្វើឡើងដូចជា ៖

• ការហត្ថលេខាយល់ព្រមនៅមុខមន្ត្រីអត្រានុកូលដ្ឋាន

• ឯកសារយល់ព្រមត្រូវបំពេញឈ្មោះគូភាគីនៃអាពាហ៍ពិពាហ៍ រួចគូភាគីនៃអាពាហ៍ពិពាហ៍ត្រូវចុះហត្ថលេខារួមគ្នា

• ការប្រកាសជាសាធារណៈដោយផ្ទាល់មាត់នៅចំពោះមុខសាក្សីសំខាន់ចំនួនពីរនាក់ នៅចំពោះមុខមន្ត្រី អត្រានុកូលដ្ឋាន។[58]

**៣.១.២.២. ការចុះសំបុត្រអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍បានកើតឡើងដោយសារការប្រកាសការយល់ព្រមរបស់ភាគីទាំងសងខាងក្នុងការយកគ្នាជាប្តីប្រពន្ធនៅមុខមន្ត្រីអត្រានុកូលដ្ឋាន។

ការចុះសំបុត្រអាពាហ៍ពិពាហ៍ តម្រូវឲ្យភាគីទាំងសងខាងភ្ជាប់ជាមួយឯកសារសំខាន់ៗដូចជា ៖

• អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃនៃភាគីទាំងសងខាង

• លិខិតបញ្ជាក់ទីលំនៅរបស់ភាគីទាំងសងខាង

• លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ពោះម៉ាយរបស់ភាគីទាំងសងខាង។ ប្រសិនបើភាគីណាមួយធ្លាប់បានលែងលះសហព័ទ្ធបីមុន ភាគីនោះត្រូវបង្ហាញពីសាលក្រមឬសាលដីការបស់តុលាការ។[59]

• កិច្ចសន្យាស្តីពីកិច្ចសន្យាអាពាហ៍ពិពាហ៍ ( ប្រសិនបើមាន )[60]

គូភាគីទាំងសងខាងអាចចុះសំបុត្រអាពាហ៍ពិពាហ៍នៅការិយល័យថ្នាក់ក្រោមឬនៅការិយាល័យថ្នាក់ស្រុកនៅទូទាំងប្រទេស។

អាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងបន្ទាប់ពីការចុះសំបុត្រអាពាហ៍ពិពាហ៍។ សំបុត្រអាពាហ៍ពិពាហ៍ត្រូវចាត់ទុកជាភស្តុតាងនៃការរៀបអាពាហ៍ពិពាហ៍។[61]

## ៣.២ អនុភាពនៃការរៀបអាពាហ៍ពិពាហ៍

ក្រោយពីភាគីទាំងសងខាងបានបំពេញលក្ខខណ្ឌសុពលភាពនិងលក្ខខណ្ឌទម្រង់រួចរាល់នៃនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ដែលច្បាប់បានចែងរួចហើយ នោះអនុភាពនៃអាពាហ៍ពិពាហ៍នឹងកើតមានឡើង[62] ហើយ

[58] Thai Civil and Commercial Code , Section 1455
[59] www.thaiembassy.com/family/marriagee-in-thailand
[60] Thai Civil and Commercial Code , Section 1466
[61] www.siam-legal.com/thailand_service/thailand-marriage-laws.php
[62] Thai Civil and Commercial Code , Section 1457

គូភាគីនឹងក្លាយទៅជាសហព័ទ្ធនឹងគ្នាទៅតាមផ្លូវច្បាប់។ នៅក្នុងឋានៈជាសហព័ទ្ធនឹងគ្នា ច្បាប់បានផ្តល់សិទ្ធិនិងករណីយកិច្ចមួយចំនួនដល់សហព័ទ្ធដែលទាក់ទងទៅនឹងទិដ្ឋភាពផ្ទាល់ខ្លួននិងទិដ្ឋភាពទាក់ទងទៅនឹងការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិសម្រាប់គ្រួសារ។

### ៣.២.១. ករណីយកិច្ចរួមរស់ជាមួយគ្នា

ប្តីនិងប្រពន្ធត្រូវចេះថែរក្សា និងគាំទ្រគ្នាទៅវិញទៅមកទៅតាមសមត្ថភាពនិងលក្ខខណ្ឌជីវិត។[63] ប្តីប្រពន្ធត្រូវរួមរស់ហើយសហការសង្គ្រោះគ្នាទៅវិញទៅមកពីព្រោះអាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធផ្លូវចិត្ត រាងកាយសេដ្ឋកិច្ចនៃប្តីប្រពន្ធ។ នៅក្នុងគ្រួសារប្តីប្រពន្ធត្រូវមានភាពស្មើភាពគ្នាលើគ្រប់ទស្សនៈនិងមានករណីយកិច្ចស្រលាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នានិងជួយគ្នាទៅវិញទៅមកដើម្បីឈានទៅវឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយដែលមានសាមគ្គីភាពប្រកបដោយសុភមង្គលហើយទទ្ទឹមគ្នានេះដើម្បីឆ្លើយតបទៅនឹងករណីយកិច្ចនេះគឺពួកគេមានសិទ្ធិស្មើៗគ្នានៅក្នុងគ្រួសារ។

នៅក្នុងព្រះរាជាណាចក្រថៃ នៅក្នុងករណីដែលសហព័ទ្ធមិនអាចរួមរស់ដោយសុភមង្គលជាមួយនឹងគ្នាបានដោយការរស់នៅអាចបង្កទៅជាបញ្ហាផ្លូវកាយផ្លូវចិត្តឬអាចប៉ះពាល់ទៅដល់សុខុមាលភាពធ្ងន់ធ្ងរដែលប្តីប្រពន្ធមិនអាចមានលទ្ធភាពរួមរស់ជីវភាពជាប្តីប្រពន្ធបានដូចធម្មតា សហព័ទ្ធដែលរងគ្រោះអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីអនុញ្ញាតឲ្យសហព័ទ្ធដែលរងគ្រោះអាចរស់នៅដាច់ដោយឡែកបាន។ តុលាការក៏អាចបង្គាប់ឲ្យផ្តល់នូវថវិកាផងដែរនៅក្នុងការចំណាយនានាផ្អែកតាមស្ថានភាពជាក់ស្តែង។[64]

### ៣.២.២. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅពេលដែលរៀបអាពាហ៍ពិពាហ៍ តើនឹងធ្វើឲ្យជះឥទ្ធិពលបែបណាទៅដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ។ ផ្អែកតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ នៅពេលដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង គឺទ្រព្យសហព័ទ្ធត្រូវបានបែងចែកជាពីរប្រភេទ គឺប្រព័ន្ធទ្រព្យដែលកំណត់តាមកិច្ចសន្យានិងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។

ទ្រព្យសម្បត្តិរបស់សហព័ទ្ធគឺជាមូលដ្ឋានដែលកំណត់ដោយច្បាប់រួមមានទ្រព្យសម្បត្តិដោយឡែកគឺជាប្រព័ន្ធដែលមិនធ្វើឲ្យប៉ះពាល់ទៅដល់ប្តីប្រពន្ធទេ ទោះបីជាបានរៀបអាពាហ៍ពិពាហ៍ក៏ដោយនិងទ្រព្យសម្បត្តិរួមគឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលនឹងមានផលប៉ះពាល់ទៅដល់ប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយទ្រព្យទាំងនោះត្រូវក្លាយជាទ្រព្យរួម។[65]

---

[63] **Thai Civil and Commercial Code , Section 1461**
[64] **Thai Civil and Commercial Code , Section 1462**
[65] ការបកស្រាយប្រព័ន្ធអំពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធ , **Masayuki Tanamura , Professor Of Law , Wanseda University** , ទំព័រ ១

**៣.២.២.១. ទ្រព្យសម្បត្តិតាមកិច្ចសន្យា**

នៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានកើតឡើង ទ្រព្យសម្បត្តិគ្រួសាររបស់ពួកគេក៏ត្រូវបានក៏ចាប់ផ្តើមដំណើរការវិវឌ្ឍន៍ព្រមគ្នាដែរ។ ប្រព័ន្ធទ្រព្យសម្បត្តិយោងតាមវិធានកិច្ចសន្យា ជាប្រព័ន្ធគំរូមួយអនុវត្តន៍ទៅលើការកំណត់ ការចាត់ចែងនិងគ្រប់គ្រងទ្រព្យក្នុងរង្វង់គ្រួសារ ហើយក៏ជាប្រព័ន្ធដែលទទួលយកដោយច្បាប់ផងដែរ ធៀបទៅនឹងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមការរៀបចំរបស់ច្បាប់។

សហព័ទ្ធមានសេរីភាពក្នុងការសំដែងឆន្ទៈព្រមព្រៀងទាំងសងខាងក្នុងការបង្កើតកិច្ចសន្យាគ្រប់គ្រងទ្រព្យរបស់ខ្លួនក្នុងអំឡុងពេលមានអាពាហ៍ពិពាហ៍ដោយរាប់បញ្ចូលនូវឧបញ្ញត្តិពិសេសផ្សេងៗ តាមការព្រមព្រៀងគ្នា។

សហព័ទ្ធទាំងសងខាង ក៏អាចមានសិទ្ធិសេរីភាពក្នុងការពិភាក្សាគ្នាទៅវិញទៅមកក្នុងការកំណត់លើបញ្ហាទ្រព្យសម្បត្តិដោយវាបានបង្កើតភាពថ្មីមួយទៀតដែលឆ្លើយតបទៅនឹងផលប្រយោជន៍របស់ខ្លួននិងមិនបំពានសិទ្ធិគ្នាទៅវិញទៅមក បានចេញជាប្រព័ន្ធគ្រប់គ្រងពិសេសថ្មីមួយសម្រាប់គ្រួសារខ្លួន។

កិច្ចសន្យាគ្រប់គ្រងទ្រព្យរបស់សហព័ទ្ធ អាចយកជាការបានលុះត្រាតែវាបានបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា ៖

- ការព្រមព្រៀងពិតប្រាកដនៃគូសហព័ទ្ធ និងដោយសេរី
- មានសមត្ថភាពចុះកិច្ចសន្យា
- មានសមត្ថភាពបង្ហាញឆន្ទៈ
- គោលបំណងនៃកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធមិនផ្ទុយទៅនឹងសីលធម៌និងសណ្តាប់ធ្នាប់សាធារណៈ ។[66]

**៣.២.២.២. ប្រព័ន្ធទ្រព្យសម្បត្តិតាមការកំណត់របស់ច្បាប់**

នៅក្នុងប្រព័ន្ធច្បាប់នៅក្នុងប្រទេសថៃ គេបានបែងចែកប្រព័ន្ធទ្រព្យសម្បត្តិជាពីរប្រភេទគឺប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។ ប្រសិនបើប្តីប្រពន្ធមិនបានជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានោះទេនៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ គឺមានន័យថាពួកគេបានជ្រើសរើសប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់។ប្រព័ន្ធទ្រព្យសម្បត្តិតាមការច្បាប់កំណត់ត្រូវបានបែងចែកជាពីរប្រភេទ គឺទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមនេះបើផ្អែកទៅលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ។

**ក.ទ្រព្យសម្បត្តិដោយឡែក**

[66] Thai Civil and Commercial Code , Section 1465

គេនិយាយថាទ្រព្យសម្បត្តិដោយឡែកបានធានានូវភាពឯករាជ្យនៃទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធហើយធ្វើឲ្យទំនាក់ទំនងគតិយុត្តិនៃទ្រព្យមានភាពច្បាស់លាស់និងធ្វើឲ្យមានសុវត្ថិភាពលើកិច្ចការជំនួញ។ផ្ទុយមកវិញក៏មានការរិះគន់ផងដែរថាប្រព័ន្ធនេះមិនអាចឆ្លុះបញ្ចាំងឲ្យឃើញពីទំនាក់ទំនងនៃការសហការផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធនិងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធខ្លាំងពេកហើយមិនអាចវាយតម្លៃបានអំពីការងារដែលប្រពន្ធត្រូវជួយគាំទ្រប្តី។[67]

ដើម្បីអាចកំណត់សម្គាល់ថាទ្រព្យសម្បត្តិណាមួយជាទ្រព្យសម្បត្តិដោយឡែក យើងអាចសម្គាល់បានដោយផ្អែកលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃដែលបានបញ្ញត្តិថា ៖

• គឺជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់សហព័ទ្ធមុនពេលរៀបអាពាហ៍ពិពាហ៍

ឧទាហរណ៍ ៖ លោក ឆៃយ៉ា និងអ្នកស្រី អារ៉ាន់យ៉ា គឺជាសហព័ទ្ធនឹងគ្នាពោលគឺពួកគេបានរៀបការនឹងគ្នាតាមច្បាប់នឹងគ្នាអស់រយៈពេល ១០ឆ្នាំ។ នៅមុនពេលដែលពួកគេមិនទាន់បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា លោក ឆៃយ៉ា មានដីធ្លីចំនួនបីកន្លែងដែលមានទីតាំងនៅក្នុងតំបន់ទេសចរណ៍ខេត្តឈៀងម៉ៃ។ រីឯ អ្នកស្រី អារ៉ាន់យ៉ា វិញនៅមុនពេលរៀបអាពាហ៍ពិពាហ៍អ្នកស្រីមានទ្រព្យសម្បត្តិជាអចលនទ្រព្យមួយកន្លែងស្ថិតនៅក្នុងខេត្តភូកេត។ ហេតុដូច្នេះច្បាប់បានកំណត់ថា ដីធ្លីចំនួនបីកន្លែងរបស់លោក ឆៃយ៉ា និងអចលនទ្រព្យមួយកន្លែងរបស់អ្នកស្រី អារ៉ាន់យ៉ា គឺជាទ្រព្យសម្បត្តិដោយឡែក។ ពួកគេអាចធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរៀងៗខ្លួនបាន។

• ទ្រព្យសម្បត្តិដែលប្តីឬប្រពន្ធទទួលបានក្នុងពេលរៀបអាពាហ៍ក្នុងលក្ខណៈជាអំណោយ ឬ មត៌ក[68]

ឧទាហរណ៍ ៖ លោក ឆាឡឹមឆៃ និងកញ្ញា កងកែវ គឺជាសង្សារបណ្តូលចិត្តនឹងគ្នានពេលដែលពួកគេកំពុងសិក្សានៅថ្នាក់ឧត្តមសិក្សាហើយបានសន្យានឹងគ្នាជាមួយគ្នាថានឹងរៀបអាពាហ៍ពាហ៍នឹងគ្នានៅពេលដែលបញ្ចប់ការសិក្សា។ នៅពេលថ្ងៃរៀបអាពាហ៍ពិពាហ៍របស់ពួកគេចូលមកដល់ម្តាយរបស់លោក ឆាឡឹមឆៃ បានប្រទានកម្មនូវផ្ទះវិឡាមួយល្វែងដែលមានតម្លៃបីលានបាតស្ថិតនៅឯខេត្តសុងខ្លា រីឯឪពុកម្តាយរបស់កញ្ញា កងកែវ វិញបានប្រទានកម្មនូវគ្រឿងអលង្ការមួយឈុតតម្លៃ១សែនបាត។ បើផ្អែកតាមប្រភពទ្រព្យដែលភាគីនៃអាពាហ៍ពិពាហ៍បានទទួលដូចជាផ្ទះវិឡា របស់លោក ឆាឡឹមឆៃ និងគ្រឿងអលង្ការមួយឈុតរបស់កញ្ញា កងកែវ គឺជាទ្រព្យសម្បត្តិដោយឡែកដែលអ្នកទាំងពីរបានទទួលជាលក្ខណៈអំណោយនៅក្នុងពេលរៀបការ។

**ខ.ទ្រព្យសម្បត្តិរួម**

មិនខុសគ្នាទៅនឹង ច្បាប់ក្រមរដ្ឋប្បវេណីខ្មែរនោះទេ គឺក្រមរដ្ឋប្បវេណីនៃប្រទេសថៃ បានបែងចែកប្រព័ន្ធទ្រព្យសម្បត្តិសហព័ទ្ធតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិសហព័ទ្ធតាមច្បាប់កំណត់ ។ ប្រព័ន្ធទ្រព្យសម្បត្តិ

[67] ការបកស្រាយប្រព័ន្ធអំពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធ , **Masayuki Tanamura , Professor Of Law , Wanseda University** , ទំព័រ ១

[68] **Thai Civil and Commercial Code , Section 1471**

សហព័ទ្ធតាមច្បាប់កំណត់ បែងចែកជាពីរគឺទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក ដើម្បីបង្កភាពងាយស្រួលនៅក្នុងកំណត់ទ្រព្យសម្បត្តិ។

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលទទួលស្គាល់អំពីអត្ថិភាពនៃទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធតាមរយៈអាពាហ៍ពិពាហ៍ក្នុងទំហំមួយដែលបានកំណត់ហើយនៅពេលដែលអាពាហ៍ពិពាហ៍រលាយ នឹងត្រូវយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមកធ្វើការបែងចែក។

ប្រព័ន្ធទ្រព្យសម្បត្តិប្រភេទនេះត្រូវបានគេយកមកប្រើប្រាស់នៅក្នុងប្រទេសបារាំង ប្រទេសកម្ពុជានិងបណ្តាប្រទេសមួយចំនួនទៀតដែលទទួលឥទ្ធិពលនៃប្រព័ន្ធនេះ។ ភាគច្រើននៃប្រទេសទាំងនោះប្រើប្រព័ន្ធដែលយកប្រាក់ចំណូលដែលប្តីប្រពន្ធរកបានពេលអំឡុងពេលអាពាហ៍ពិពាហ៍មកធ្វើជាទ្រព្យសម្បត្តិរួម។ បើទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍និងទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដែលពុំមានតម្លៃតប ត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក។ ក្នុងករណីភាគច្រើនទ្រព្យសម្បត្តិរួមគឺជាទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

ផ្ទុយមកវិញចំពោះទ្រព្យសម្បត្តិរួម គឺជាប្រព័ន្ធដែលអាចធ្វើឲ្យសម្រេចនូវការវាយតម្លៃអំពីភាពស្មើគ្នានិងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធបាន ប៉ុន្តែគុណវិបត្តិនៃប្រព័ន្ធនេះគឺធ្វើឲ្យទំនាក់ទំនងគតិយុត្តិមានភាពស្មុគស្មាញហើយធ្វើឲ្យប៉ះពាល់ដល់តតិយជននិងសុវត្ថិភាពជំនួញ។[69]

ផ្អែកតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃ ព្រទ្យសម្បត្តិរួមគឺជាទ្រព្យសម្បត្តិដែល ៖

• ជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានក្នុងពេលរៀបអាពាហ៍ពិពាហ៍

ឧទាហរណ៍ ៖ លោក កេតទិឆៃ និងអ្នកស្រី ហាតថៃ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាំងពីឆ្នាំ ២០១០។ តាំងពីពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាមក ពួកគេបានបើកអាជីវកម្មផ្នែកទេសចរណ៍បានទទួលប្រាក់ចំណេញជាច្រើននិងបានទិញដីធ្លីជាច្រើនកន្លែងនៅប្រទេសថៃ។ មួយរយៈក្រោយមកទៀតពួកគេបានយកប្រាក់ដែលចំណេញពីអាជីវកម្មខាងលើយកទៅទិញផ្ទះវីឡាមួយកន្លែង។ ជារួមទ្រព្យសម្បត្តិដែលពួកគេទាំងពីរនាក់បានរកបានដូចជាដីធ្លីជាច្រើនកន្លែងនិងផ្ទះវីឡាគឺជាទ្រព្យសម្បត្តិរួម ពីព្រោះពួកគេទាំងពីរនាក់បានទទួលនៅពេលដែលពួកគេស្ថិតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

• ទ្រព្យដែលបានធ្វើលទ្ធកម្មដោយភាគីណាមួយក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ រួចបញ្ជាក់ថាជាទ្រព្យរួមដោយឆន្ទៈភាគីទាំងសងខាង

ឧទាហរណ៍ ៖ លោក ក្រៀងក្រៃ និងអ្នកស្រី ឆាឡឹមវ៉ាន់ គឺជាគូស្វាមីភរិយាដែលបានរៀបអាពាហ៍ពិពាហ៍

[69] ការបកស្រាយប្រព័ន្ធអំពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធ , **Masayuki Tanamura , Professor Of Law , Wanseda University** , ទំព័រ ២

ជាមួយគ្នាអស់រយៈពេលចំនួន៥ឆ្នាំដោយបានបុត្រប្រុសស្រីចំនួន២នាក់ជាចំណងដៃ។ នៅមុនពេលដែលអ្នកទាំងពីររៀបអាពាហ៍ពិពាហ៍ លោក ក្រៀងក្រៃ គឺជាកូនដែលស្ថិតនៅក្នុងគ្រួសារដែលមានជីវភាពស្តុកស្តម្ភ។ លោក ក្រៀងក្រៃ មានទ្រព្យដោយឡែកដូចជាដីធ្លីចំនួនមួយកន្លែង និងទឹកប្រាក់ចំនួន១០លានបាត។ លុះដល់ពេលក្រោយមក លោក ក្រៀងក្រៃ និងអ្នកស្រី ឆាឡឹមវ៉ាន់ បានសម្រេចចិត្តទិញផ្ទះមួយកន្លែងនៅខេត្តសុផាន់បុរីក្នុងតម្លៃ២លានបាត ដោយចំណាយប្រាក់ដែលជាទ្រព្យដោយឡែករបស់លោក ក្រៀងក្រៃ ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។ បន្ទាប់មកអ្នកទាំងពីរក៏បានបង្ហាញឆន្ទៈថាផ្ទះដែលបានទិញត្រូវចាត់ទុកជាទ្រព្យរួម។

• ផលនៃទ្រព្យដោយឡែក[70]

ឧទាហរណ៍ ៖ លោក ណារ៉ុង និងអ្នកស្រី កានឆាណា គឺជាគូសហព័ទ្ធនឹងគ្នាស្របទៅតាមច្បាប់។ មុនពេលរៀបអាពាហ៍ពិពាហ៍នឹងគ្នា អ្នកទាំងពីរមានទ្រព្យសម្បត្តិមួយចំនួនផងដែរ។ លោក ណារ៉ុង មានទ្រព្យដោយឡែកជាផ្ទះមួយល្វែងដែលនៅជនបទ និងអ្នកស្រី កានឆាណាវិញមានដីចំនួន១ហិកតា ដែលស្ថិតនៅឯស្រុកកំណើតរបស់អ្នកស្រី។ អ្នកទាំងពីរបានពិភាក្សានឹងគ្នាថាដើម្បីបង្កើនចំណូលក្នុងគ្រួសារ ពួកគេគួរតែយកទ្រព្យសម្បត្តិដោយឡែកផ្ទាល់ខ្លួនទៅបង្កើតភតិសន្យាដើម្បីមានប្រាក់ចំណូលបន្ថែមទៀត។ ទ្រព្យដោយឡែករបស់ពួកគេទាំងពីរនាក់ បានទទួលចំណូលចំនួន ៥០០០០បាត នៅក្នុង១ខែពីការធ្វើភតិសន្យា។ ដូច្នេះ ទឹកប្រាក់ចំនួន៥០០០០បាតគឺជាទ្រព្យសម្បត្តិរួម ទោះបីជាផលដែលកើតចេញពីទ្រព្យដោយឡែកក៏ដោយ។

### ខ.១ ការគ្រប់គ្រងទ្រព្យសម្បត្តិរួម

ទ្រព្យរួម គឺជាទ្រព្យទាំងឡាយណាដែលសហព័ទ្ធរកបាននៅក្នុងអំឡុងចំណងអាពាហ៍ពិពាហ៍ដែលផ្ទុយពី រួមដោយឡែកដែលសហព័ទ្ធរកបាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។

ជាគោលការណ៍នៅក្នុងការគ្រប់គ្រងសម្បត្តិរួមគឺសហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិដោយសារការសហការគ្នា។[71] ប៉ុន្តែនៅក្នុងប្រទេសថៃ ច្បាប់ក៏បានបើកសិទ្ធិយ៉ាងទូលំទូលាយឲ្យគូសហព័ទ្ធអាចធ្វើកិច្ចសន្យាព្រមព្រៀងគ្នាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរួមបាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ (**PRENUPTIAL AGREEMENT**)[72] ដែលឲ្យតម្រូវឲ្យចុះបញ្ជីរួមគ្នាជាមួយសំបុត្រអាពាហ៍ពិពាហ៍នៅមុខមន្ត្រីអត្រានុកូលដ្ឋាន។[73]

---

[70] **Thai Civil and Commercial Code , Section 1474**

[71] **Thai Civil and Commercial Code , Section 1476**

[72] **Prenutial Agreement** គឺជាកិច្ចសន្យាមួយសំដៅដល់គូភាគីបានបង្កើតនូវមុនការរៀបអាពាហ៍ពិពាហ៍ដែលកិច្ចសន្យានេះចែងអំពីខសន្យាអំពីលក្ខខណ្ឌនានានៃអំឡុងពេលនៃការរៀបអាពាហ៍ ដូចជា ការគ្រប់គ្រងទ្រព្យសម្បត្តិ ការលែងលះជាដើម។

[73] **Thai Civil and Commercial Code , Section 1476 (1)**

ការបង្កើតកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិរួមតម្រូវឲ្យគូភាគីនៃអាពាហ៍ពិពាហ៍សរសេរកិច្ចសន្យាដោយផ្ទាល់ដៃនិងត្រូវចុះហត្ថលេខាទាំងពីរនាក់នៅមុខសាក្សីពីរនាក់នៅមុខមន្ត្រីអត្រានុកូលដ្ឋានដែលកិច្ចសន្យានេះអាចបន្ថែមនូវឧបសម្ព័ន្ធមួយចំនួនស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរួម។ នៅពេលកិច្ចសន្យាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិចុះបញ្ជីរួចហើយ គូភាគីនៃការរៀបអាពាហ៍ពិពាហ៍មិនអាចកែប្រែខសន្យានៅក្នុងកិច្ចសន្យាបានទេលើកលែងតែការកែប្រែរបស់តុលាការ។[74]

នៅក្នុងកិច្ចសន្យាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរួមនេះផងដែរ គូភាគីនៃអាពាហ៍ពិពាហ៍អាចចែងនូវបទបញ្ញត្តិស្តីពីការគ្រប់គ្រងនូវផ្នែកណាមួយ ឬគ្រប់គ្រងទាំងស្រុងនៃទ្រព្យសម្បត្តិរួមដែលកិច្ចសន្យានេះមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឬសីលធម៌ល្អរបស់សង្គម។[75]នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួមតាមកិច្ចសន្យានេះដែរ សហព័ទ្ធម្ខាងៗអាចផ្ទេរសិទ្ធិនៃការគ្រប់គ្រងទៅតតិយជនបាន ប៉ុន្តែមិនអាចផ្ទេរហួសពីទំហំនៃទ្រព្យសម្បត្តិរបស់ខ្លួនឡើយ។[76] នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួម ប្រសិនបើសហព័ទ្ធណាម្ខាងបានគ្រប់គ្រងដោយភាពមិនត្រឹមដែលអាចបណ្តាលឲ្យខូចខាតដល់ទ្រព្យសម្បត្តិរួម[77] ភាគីម្ខាងទៀតអាចដាក់ពាក្យទៅតុលាការដើម្បីហាមឃាត់សកម្មភាពនេះបាន។[78]

### ខ.២ ការចាត់ចែងទ្រព្យសម្បត្តិរួម

ដូចបានបញ្ជាក់នៅផ្នែកខាងលើ នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួមគឺសហព័ទ្ធអាចគ្រប់គ្រងទ្រព្យសម្បត្តិរួមតាមរយៈការសហការគ្នានិងតាមរយៈកិច្ចសន្យាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរួម។ ប៉ុន្តែនៅក្នុងករណីចាត់ចែងទ្រព្យសម្បត្តិរួមវិញគឺច្បាប់នៃប្រទេសថៃតម្រូវឲ្យសហព័ទ្ធម្ខាងត្រូវការការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដើម្បីអាចចាត់ចែងទ្រព្យសម្បត្តិរួមបាន។

ភាគីម្ខាងនៃសហព័ទ្ធត្រូវសុំការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដើម្បីអាចចាត់ចែងទ្រព្យសម្បត្តិរួមនៅក្នុងករណីដូចជា ៖

- ការធ្វើកិច្ចសន្យាលក់ ឬ កិច្ចសន្យាដូរ
- ការធ្វើកិច្ចសន្យាខ្ចីប្រាក់
- ការធ្វើកិច្ចសន្យាជួលអចលនវត្ថុលើសពីបីឆ្នាំ
- ការធ្វើកិច្ចសន្យាប្រទានកម្ម[79]

[74] **Thai Civil and Commercial Code , Section 1467**
[75] **Thai Civil and Commercial Code , Section 1465**
[76] **Thai Civil and Commercial Code , Section 1481**
[77] **Thai Civil and Commercial Code , Section 1483**
[78] **Thai Civil and Commercial Code , Section 1482**
[79] **Thai Civil and Commercial Code , Section 1476**

នៅក្នុងករណីដែលសហព័ទ្ធម្ខាងបានចាត់ចែងនូវទ្រព្យសម្បត្តិរួមដែលពុំមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត សហព័ទ្ធនោះអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីទទួលបានការអនុញ្ញាត។[80] នៅពេលដែលសហព័ទ្ធណាម្ខាងបានចាត់ចែងទ្រព្យសម្បត្តិរួមនៅក្នុងករណីដែលមិនមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬតុលាការ សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រមអាចលុបចោលនូវការចាត់ចែងនោះបាននៅអំឡុងពេល ១ ឆ្នាំ គិតចាប់ពីបានដឹងអំពីការចាត់ចែងនោះ ឬរយៈពេល១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះ។[81]

**៣.២.៣. ការទទួលខុសត្រូវរួមគ្នាចំពោះកាតព្វកិច្ច**

បន្ទាប់ពីអាពាហ៍ពិពាហ៍រួច ក្រៅពីករណីយកិច្ចរួមរស់ជីវភាពជាមួយគ្នានិងសិទ្ធិនៅក្នុងការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្នុងគ្រួសារ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រថៃបានបញ្ញត្តិនូវចំណុចពិសេសមួយទៀតគឺការទទួលខុសត្រូវរួមគ្នាចំពោះកាតព្វកិច្ចដែលបានកើតឡើងនៅក្នុងគ្រួសារ។ ដូចនេះការទទួលខុសត្រូវរួមគ្នារបស់សហព័ទ្ធចំពោះកាតព្វកិច្ចគឺជាការទទួលខុសត្រូវនៅក្នុងគ្រួសារទាំងមូលនៅពេលដែលកាតព្វកិច្ចនោះត្រូវបានកើតឡើងដែលមានការពាក់ព័ន្ធទៅនឹងការរ៉ាប់រងផលប្រយោជន៍ក្នុងគ្រួសារ ឬការអប់រំ និងការសិក្សារបស់ កូន។

នៅក្នុងករណីដែលកាតព្វកិច្ចដែលបានកើតឡើងដោយសារឆន្ទៈរបស់ភាគីម្ខាងដែលកាតព្វកិច្ចនោះបានពាក់ព័ន្ធទៅនឹងផលប្រយោជន៍ផ្ទាល់ខ្លួន ឬមិនឆ្លើយតបទៅនឹងផលប្រយោជន៍នៅក្នុងគ្រួសារដែលភាគីម្ខាងទៀតមិនបានយល់ព្រមជាមួយម្ចាស់បំណុល កាតព្វកិច្ចនោះគឺជាកាតព្វកិច្ចដោយឡែករបស់សហព័ទ្ធម្ខាងគឺមិនមានការទទួលខុសត្រូវរួមគ្នាទេចំពោះកាតព្វកិច្ចនោះ។

តាមច្បាប់នៃប្រទេសថៃ សហព័ទ្ធទាំងពីរត្រូវមានករណីយកិច្ចទទួលខុសត្រូវរួមគ្នាចំពោះកាតព្វកិច្ចដែលបានកើតឡើងប្រសិនបើកាតព្វកិច្ចនោះគឺជា ៖

- កាតព្វកិច្ចដែលបានកើតឡើងទាក់ទងទៅនឹងការគ្រប់គ្រងការងារនៅក្នុងគ្រួសារ និងការផ្គត់ផ្គង់តម្រូវការចាំបាច់នៅក្នុងគ្រួសារ
- កាតព្វកិច្ចដែលកើតមានឡើងពាក់ព័ន្ធនឹងការថែទាំសុខភាពនៅក្នុងគ្រួសារនិងការអប់រំរបស់កូន
- បំណុល ឬ សោហ៊ុយដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរួម
- កាតព្វកិច្ចដែលកើតចេញពីអាជីវកម្មរួមគ្នារបស់សហព័ទ្ធទាំងពីរបានធ្វើរួមគ្នា
- កាតព្វកិច្ចនិងករណីយកិច្ចដែលប្តីឬប្រពន្ធទាំងសងខាងបានយល់ព្រម ឬ កាតព្វកិច្ច និងករណីយកិច្ចផ្សេងទៀតដែលប្តីប្រពន្ធណាម្ខាងបានទទួលបន្ទុកដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។

[80] **Thai Civil and Commercial Code , Section 1478**
[81] **Thai Civil and Commercial Code , Section 1480**

ឧទាហរណ៍ ៖ លោក ប៉ូវីប៊ុន និងអ្នកស្រី ប៊ូសារ៉ាខាម បានរៀបការជាមួយគ្នាអស់រយៈពេល១០ឆ្នាំ និងមានបុត្របុត្រីចំនួនពីរនាក់ជាចំណងដៃ។ ពួកគេទាំងពីរនាក់មានមុខរបរជាកម្មកររោងចក្រដែលទទួលបានប្រាក់បៀវត្សសមរម្យនៅក្នុងការផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ។ ដោយចង់ឲ្យកូនទាំងពីរបានចូលសិក្សា អ្នកស្រី ប៊ូសារ៉ាខាម ក៏បានខ្ចីប្រាក់ពីសាច់ញាតិចំនួន១០០០០បាត សម្រាប់ការចំណាយនានានៅការសិក្សារបស់កូន។ នៅក្នុងករណីបែបនេះទោះបីលោក ប៉ូវីប៊ុន មិនបានចូលរួមខ្ចីប្រាក់ ឬមិនបានផ្តល់ការយល់ព្រមនៅក្នុងការខ្ចីប្រាក់នេះក៏ដោយ ក៏លោក ប៉ូវីប៊ុន នៅមានកាតព្វកិច្ចទទួលខុសត្រូវរួមជាមួយអ្នកស្រី ប៊ូសារ៉ាខាម ផងដែរនៅក្នុងការខ្ចីបំណុលខាងលើពីព្រោះវាគឺកាតព្វកិច្ចដែលផ្គត់ផ្គង់នៅក្នុងគ្រួសារតួយ៉ាងគឺដើម្បីការសិក្សារបស់កូន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានចងក្រងនូវសារណាមួយនេះ ពួកយើងសង្កេតឃើញថា ប្រពៃណីទំនៀមទំលាប់នៃការរៀបអាពាហ៍ពិពាហ៍នៃប្រទេសកម្ពុជា និង ថៃ មានលក្ខណៈស្រដៀងដោយហេតុថាប្រទេសទាំងពីរជាប្រទេសភូមិផងរបងជាមួយជាហេតុនាំឲ្យមានការទទួលឥទ្ធិពលទំនៀមទំលាប់ប្រពៃណីរវាងគ្នាទៅវិញទៅមក ប៉ុន្តែបើយើងសង្កេតមើលលើទិដ្ឋភាពផ្លូវគតិយុត្តិវិញ គឺនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍របស់ប្រទេសកម្ពុជា និងថៃ គឺមានលក្ខណៈដូចគ្នា គឺភាគីនៃអាពាហ៍ពិពាហ៍ត្រូវតែគោរពទៅតាមលក្ខខណ្ឌសារធាតុ និងលក្ខខណ្ឌទម្រង់ គ្រាន់តែមានចំណុចខុសគ្នាបន្តិចបន្តួចនៅចំណុចស្នូលនៃលក្ខខណ្ឌសារធាតុ។

លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍នៃប្រទេសកម្ពុជា បានកំណត់អាយុដែលភាគីអាចរៀបអាពាហ៍ពិពាហ៍បានគឺតម្រូវឲ្យភាគីទាំងពីរមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ឬ ភាគីម្ខាងមានអាយុមិនតិចជាង ១៦ឆ្នាំ ប្រសិនបើមានការយល់ព្រមពីអ្នកមានអំណាចមេបា ដែលខុសពីលក្ខខណ្ឌអាយុនៃការរៀបអាពាហ៍ពិពាហ៍នៃប្រទេសថៃ ដែលច្បាប់នៃប្រទេសថៃបានកំណត់លក្ខខណ្ឌអាយុនៃការរៀបអាពាហ៍ពិពាហ៍ត្រឹមតែអាយុ ១៧ ឆ្នាំ ឬក៏អាចតិចជាងនេះ ប្រសិនបើមានការអនុញ្ញាតពីតុលាការ។ មួយវិញទៀតច្បាប់នៃប្រទេសកម្ពុជា បានកំណត់គោលការណ៍វិធវភាពចំពោះស្ត្រី ត្រឹមតែ ១២០ថ្ងៃប៉ុណ្ណោះ គិតចាប់តាំងពីអាពាហ៍ពិពាហ៍ចាស់បានរំលាយ ប៉ុន្តែបើយើងក្រឡេកមើលច្បាប់នៃប្រទេសថៃវិញបានកំណត់គោលការណ៍វិធវភាពចំពោះស្ត្រីរហូតដល់រយៈពេល ៣០០ ថ្ងៃ ដែលខុសគ្នាយ៉ាងខ្លាំងទៅនឹងច្បាប់នៃប្រទេសកម្ពុជា ។

រីឯ លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍នៃប្រទេសទាំងពីរ គឺមានលក្ខណៈដូចគ្នាទាំងស្រុង គឺតម្រូវឲ្យភាគីនីមួយនៃអាពាហ៍ពិពាហ៍ ដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ និង ចុះបញ្ជីអាពាហ៍ពិពាហ៍ នៅមុខមន្ត្រីអត្រានុកូលដ្ឋាននៅចំពោះមុខសាក្សីពីរនាក់។

# អនុសាសន៍

ក្រោយពីបានស្រាវជ្រាវ និង សរសេរចងក្រងនូវសារណាបញ្ចប់ការសិក្សាមួយនេះមកពួកយើងទាំងពីរនាក់បានមើលឃើញថាការរៀបអាពាហ៍ពិពាហ៍មួយដែលស្របទៅតាមនីតិវិធីច្បាប់ ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សហព័ទ្ធ។ ប៉ុន្តែប្រជាពលរដ្ឋខ្មែរមួយចំនួននៅតាមតំបន់ជនបទនិងតំបន់ដាច់ស្រយាលមិនទាន់យល់ដឹងពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ច្បាស់នៅឡើយ ដែលជាដើមហេតុធ្វើឲ្យពួកគេតែងតែរៀបអាពាហ៍ពិពាហ៍ទៅតាមទម្រង់ប្រពៃណីដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមច្បាប់ដែលនានាកំពុងអនុវត្ត។

ដោយមើលយោងតាមទស្សនៈរបស់ក្រុមយើងខ្ញុំ ពួកយើងគួរគប្បីធ្វើការផ្សព្វផ្សាយឲ្យបានជ្រាបនូវទិដ្ឋភាពច្បាប់សំខាន់ៗមួយចំនួនមិនមែនត្រឹមច្បាប់ស្ដីអំពីអាពាហ៍ពិពាហ៍នោះទេ។ ជាពិសេសសម្រាប់ប្រទេសកម្ពុជាយើង គឺប្រជាពលរដ្ឋភាគច្រើននៅតែជាប់ជិតដាមនឹងទំនាមទំលាប់ ប្រពៃណី ដោយហេតុថាពួកគាត់មិនបានដឹងអំពីច្បាប់ដែលការពារលើសិទ្ធិ និងផលប្រយោជន៍របស់ពួកគេ។

ជាពិសេសបំផុតនោះគឺ ក៏ត្រូវតែមានការចូលរួមដោយម៉ត់ចត់ពីសំណាកអាជ្ញាធរដែនដី ដែលត្រូវមានភាពអត់ធ្មត់ខ្ពស់ក្នុងការផ្ដល់នូវដំណឹងឬជាមតិជូនដល់ប្រជាពលរដ្ឋរបស់ខ្លួនទៅតាមតម្រូវការជាក់ស្ដែង ក៏ដូចជាការផ្ដល់នូវសេវាកម្មដែលមានភាពល្អប្រសើរទៅដល់ពួកគាត់ ដែលភាគច្រើនតែងតែជួបប្រទះនូវកង្វះសម្ភារៈដូចជាលិខិតអាពាហ៍ពិពាហ៍ផ្សេងៗក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអាចជាសេវាដូចជានៅពេលដែលប្រជាពលរដ្ឋមានតម្រូវការ ត្រូវការសហការប៉ុន្តែពុំបានទទួលសេវាទាន់ពេលវេលា ឬភាពយឺតយ៉ាវក្នុងការផ្ដល់ជូន។

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តិ

ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

Thai Civil and Commercial Code ( BE 2468 , 1925 )

ច្បាប់ស្តីពីឯកពន្ធភាព ២០០៦

អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ២០០០

## សៀវភៅជំនួយស្មារតី

សៀវភៅ នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ ២០១៧ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង សាស្ត្រាចារ្យ ចាំង ស៊ីណាត

សៀវភៅ នីតិបេតិកភណ្ឌគ្រួសារ ២០១២ រៀបរៀងដោយ សាស្ត្រាចារ្យ ស្រី វណ្ណធី

សៀវភៅ អរិយធម៌ខ្មែរ រៀបរៀងដោយ អ្នកស្រី ត្រឹង ងា ១៩៧៤

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
